ប្រសិនបើលោកអ្នកចង់ជាវសៀវភៅនេះ សូមចូលទៅកាន់គេហទំព័រ
For purchase information please visit
www.cambodianchristianresources.com/dfd

# ជីវិតរបស់លោកអ្នក នៅក្នុងព្រះគ្រីស្ទ

*គម្រោងនៃការបង្កើតសិស្ស*

## គបស១

NavPress
Discipleship Inside Out®

សាឡូមកម្ពុជា
www.smcambodia.org

NAVPRESS
Discipleship Inside Out®

NavPress គឺជាព័ន្ធកិច្ចនៃការបោះពុម្ពរបស់ The Navigators ដែលជាអង្គការគ្រីស្ទបរិស័ទអន្តរជាតិ ហើយជាអង្គការដែលឈានមុខគេខាងការអភិវឌ្ឍផ្នែកព្រលឹងវិញ្ញាណរបស់មនុស្ស។ NavPress បានប្ដេជ្ញាចិត្តក្នុងការជួយមនុស្សឲ្យមានការលូតលាស់ផ្នែកព្រលឹងវិញ្ញាណ ហើយឲ្យមានអំណរទៅនឹងជីវិតដ៏មានន័យ ព្រមទាំងឲ្យមានសង្ឃឹមតាមរយៈធនធាននៃការសិក្សាផ្ទាល់ខ្លួន ឬការសិក្សាជាក្រុមដែលក្រុម The Navigators បាននិពន្ធ ពីព្រោះមូលដ្ឋានគ្រឹះនៃធនធានទាំងនេះបានដកស្រង់ចេញពីព្រះគម្ពីរ ហើយក៏ផ្ដល់ភាពងាយស្រួលក្នុងការអនុវត្តដល់វប្បធម៌ផ្សេងៗទៀតផងដែរ។

បកប្រែដោយ៖ បេសកកម្មសាឡូមកម្ពុជា និង សកម្មភាពកម្ពុជា
Translated by: Shalom Mission Cambodia - http://www.smcambodia.org
and ACTION Cambodia - http://www.actioncambodia.org

ពិនិត្យផ្ទៀងផ្ទាត់ដោយ៖ លោកគ្រូ សាំង ឈិនហួរ, លោកគ្រូ ហុង សុភក្ដិ, លោក ជួប ប៊ុនហាក់,
លោក ផេង វណ្ណៈ, លោក ឈាង ប៉ូរ៉ា, លោក ម៉ែន ជំនោ និង សកម្មភាពកម្ពុជា

សូមថ្លែងអំណរអរគុណដល់ លោក គឹម សីហា, លោក មាស ម៉ាដែស, លោក សួន សាយ័ន្ត, អ្នកស្រី ឆាយ សូដាលីន និង កញ្ញា សុគន្ធ ចិន្ដាមណី ដែលមានចំណែកក្នុងការអភិវឌ្ឍសៀវភៅនេះ។

ក្រុមយើងខ្ញុំបានរក្សាអក្ខរាវិរុទ្ធនៃសម្រង់ខគម្ពីរដែលមាននៅក្នុងព្រះគម្ពីរបកប្រែចាស់ឆ្នាំ១៩៥៤ ក៏ដូចជាអសាធារណនាមមួយចំនួន ប៉ុន្ដែសំណេរនៅក្នុងអត្ថបទទាំងមូល យើងខ្ញុំបានខិតខំព្យាយាមគោរពតាមអក្ខរាវិរុទ្ធនៃវចនានុក្រមខ្មែររបស់សម្ដេចសង្ឃរាជ ជួន ណាត។
ព្រមជាមួយនឹងការប្រើប្រាស់កម្មវិធីត្រួតពិនិត្យអក្ខរាវិរុទ្ធ
និងវេយ្យាករណ៍ យូនីកូដខ្មែរ របស់ ស.ស.ឈ.ន.ក.
Using the SBBIC Unicode Khmer Spelling Checker
and Grammar Checker - http://www.sbbic.org

© 1973, 1980, 2006, 2013 by The Navigators
រក្សាសិទ្ធិគ្រប់យ៉ាង © ១៩៧៣, ១៩៨០, ២០០៦, ២០១៣ ដោយ The Navigators
All rights reserved. No part of this publication may be reproduced in any form without written permission from NavPress, P.O. Box 35001, Colorado Springs, CO 80935.
www.navpress.com

NAVPRESS and the NAVPRESS logo are registered trademarks of NavPress. Absence of ® in connection with marks of NavPress or other parties does not indicate an absence of registration of those marks.

ISBN 978-0-9890481-0-1

Cover design by Arvid Wallen
Cover illustration by Michael Halbert
Interior design by The DesignWorks Group
រចនាអត្ថបទភាសាខ្មែរ ៖ លោក សេង ធា និង លោក ម៉ែន ជំនោ
Creative Team: Dan Rich, Kathy Mosier, Arvid Wallen, Pamela Poll, Pat Reinheimer, Kathy Guist
Original DFD Author: Chuck Broughton
Revision Team: Dennis Stokes, Judy Gomoll, Christine Weddle, Ralph Ennis
អត្ថបទគម្ពីរ © រក្សាសិទ្ធិដោយសមាគមព្រះគម្ពីរសកល-ដកស្រង់ដោយមានការអនុញ្ញាត
Printed in Cambodia

# គបស១ | មាតិកា


មិនមែនដោយសារតែនំប៉័ងប៉ុណ្ណោះទេ ៥

**ជំពូកទី១**
ព្រះជាម្ចាស់យកព្រះទ័យទុកដាក់ចំពោះលោកអ្នក ៩

**ជំពូកទី២**
បុគ្គលភាពនៃព្រះយេស៊ូវគ្រីស្ទ ២៩

**ជំពូកទី៣**
ព័ន្ធកិច្ចរបស់ព្រះគ្រីស្ទ ៥៣

**ជំពូកទី៤**
ព្រះវិញ្ញាណដែលគង់នៅក្នុងលោកអ្នក ៧១

# មិនមែនដោយសារតែនំប៉័ងប៉ុណ្ណោះទេ

មនុស្សរាប់កោដិនាក់បានឆ្លងកាត់នូវជីវិតដែលខ្សត់ខ្សោយខាងឯព្រលឹងវិញ្ញាណ។ ព្រះបន្ទូលដែលព្រះយេស៊ូវបានមានបន្ទូលជាច្រើនសតវត្សកន្លងមកហើយនៅតែជាព្រះបន្ទូលដ៏ពិតដដែលគឺថា “មនុស្សមិនមែនរស់ ដោយសារតែនំប៉័ងប៉ុណ្ណោះទេ គឺរស់ដោយសារគ្រប់ទាំងព្រះបន្ទូល ដែលចេញពីព្រះឱស្ឋព្រះមកដែរ” (ម៉ាថាយ ៤:៤)។

មានមនុស្សជាច្រើនដែលត្រឡប់មកសិក្សាព្រះគម្ពីរយ៉ាងម៉ត់ចត់វិញរួមទាំងអ្នកជឿព្រះយេស៊ូវថ្មីៗ និងអ្នកដែលបានស្គាល់ទ្រង់យូរមកហើយក្តី ដោយសារតែគេទទួលស្គាល់ថា ពួកគេត្រូវការព្រះបន្ទូលដែលចេញពីព្រះឱស្ឋព្រះជាម្ចាស់ជាចាំបាច់។

យើងបានរៀបចំសៀវភៅ ***គម្រោងនៃការបង្កើតសិស្ស*** នេះយ៉ាងម៉ត់ចត់ដើម្បីជួយលោកអ្នកក្នុងការៈ

- បង្កើតគម្រោងផ្ទាល់ខ្លួនមួយក្នុងការសិក្សាព្រះបន្ទូល។
- ត្រួតពិនិត្យពីសេចក្តីពិតដ៏សំខាន់ៗនៅក្នុងព្រះគម្ពីរ និងដើម្បីជួយលោកអ្នកក្នុងការពិនិត្យលើការឆ្លើយតបរបស់លោកអ្នកទៅនឹងសេចក្តីពិតទាំងអស់នោះ។
- រៀន ហើយនិងអនុវត្តពីសារៈសំខាន់នៃភាពជាសិស្ស។

ដើម្បីទទួលបាននូវអត្ថប្រយោជន៍ដ៏ពេញលេញនៃវគ្គសិក្សានេះ ការសំខាន់គឺលោកអ្នកត្រូវសិក្សាទៅតាមលំដាប់លំដោយចាប់ពីសៀវភៅទី១រហូតដល់សៀវភៅទី៧។

អ្វីដែលលោកអ្នកត្រូវការដើម្បីចាប់ផ្តើមគឺ ព្រះគម្ពីរតែប៉ុណ្ណោះ។ រាល់សំណួរនីមួយៗក្នុងសៀវភៅនេះនឹងនាំលោកអ្នកទៅឯអត្ថបទនៃព្រះគម្ពីរ។ បន្ទាប់ពីការគិតពិចារណាអំពីអត្ថបទរួចហើយ សូមសរសេរចម្លើយចេញពីទស្សនៈរបស់លោកអ្នកផ្ទាល់។

ឧយោងនៃបទគម្ពីរនីមួយៗសំដៅលើ កណ្ឌគម្ពីរ ជំពូក និង ខ។ ឧទាហរណ៍ៈ វិវរណៈ ៣:២០ មានន័យថាវាស្ថិតក្នុងកណ្ឌគម្ពីរ វិវរណៈ ជំពូក៣ និងខ២០។

សូមអធិស្ឋានមុននឹងលោកអ្នកចាប់ផ្តើមសិក្សាជំពូកនីមួយៗ។ លោកអ្នកអាចអធិស្ឋានសូមព្រះជាម្ចាស់ប្រទានប្រាជ្ញា នៅពេលលោកអ្នកសិក្សាប្រធានបទនីមួយៗខាងក្រោមនេះ៖

- ព្រះជាម្ចាស់យកព្រះទ័យទុកដាក់ចំពោះលោកអ្នក
- បុគ្គលភាពនៃព្រះយេស៊ូវគ្រីស្ទ
- ព័ន្ធកិច្ចរបស់ព្រះគ្រីស្ទ
- ព្រះវិញ្ញាណដែលគង់នៅក្នុងលោកអ្នក

នៅខាងចុងនៃជំពូកនីមួយៗ លោកអ្នកនឹងមានឱកាសមួយក្នុងការសរសេរចុះនូវគំនិត និងអារម្មណ៍របស់លោកអ្នក។ សូមធ្វើការនេះតាមការយល់ឃើញរបស់លោកអ្នកដើម្បីៈ

- **សរសេរសំណួរ**ដែលលោកអ្នកនៅតែមាននៅក្នុងចិត្ត
- **សរសេរចម្លើយ**ដែលមានសារៈសំខាន់ចំពោះលោកអ្នក
- **បង្កើតនូវគំនិតច្នៃប្រឌិត** (ដូចជាការតែងកំណាព្យ ការគូរគំនូរ។ល។)
- **សរសេរកំណត់ហេតុ**
- **ចូលឲ្យបានស៊ីជម្រៅ**ទៅលើប្រធានបទ
- **សង្ខេបគំនិត** និងអារម្មណ៍ផ្សេងៗ

លោកអ្នកនឹងមានការផ្សងព្រេងមួយ នៅពេលដែលលោកអ្នកធ្វើឲ្យទំនាក់ទំនងលោកអ្នកជាមួយព្រះគ្រីស្ទបានរឹងមាំ។

ជំពូកទី

# ១

# ព្រះជាម្ចាស់យកព្រះទ័យ ទុកដាក់ចំពោះលោកអ្នក

លោកអ្នកគឺជាមនុស្សដ៏ពិសេសម្នាក់ ព្រោះព្រះជាម្ចាស់មានបន្ទូលថា លោកអ្នកមានតម្លៃចំពោះទ្រង់។ ព្រះជាម្ចាស់យកព្រះទ័យទុកដាក់ចំពោះលោកអ្នក និងរាល់អ្វីៗដែលកើតឡើងចំពោះលោកអ្នកយ៉ាងពិតប្រាកដ។

នៅក្នុងជំពូកនេះ លោកអ្នកនឹងរៀនពីប្រយោគចំនួន៤ ដែលទាក់ទងនឹងការយកព្រះទ័យទុកដាក់របស់ទ្រង់ចំពោះលោកអ្នក៖

- ព្រះជាម្ចាស់បានបង្កើតលោកអ្នក
- ព្រះជាម្ចាស់គង់នៅគ្រប់ទីកន្លែង ហើយទ្រង់ស្គាល់លោកអ្នក
- ព្រះជាម្ចាស់ស្រឡាញ់លោកអ្នក
- ព្រះជាម្ចាស់បានយកលោកអ្នកមកធ្វើជាបុត្រចិញ្ចឹមនៅក្នុងគ្រួសាររបស់ទ្រង់

# ព្រះជាម្ចាស់បានបង្កើតលោកអ្នក



ការចាប់ផ្ដើមដ៏អស្ចារ្យទាំងអស់កើតឡើងមកពីព្រះហឫទ័យ និងគម្រោងរបស់ព្រះជាម្ចាស់។ ព្រះជាម្ចាស់ទ្រង់ផ្ទាល់គឺអស្ចារ្យបំផុត ហើយគ្មានទីបញ្ចប់ឡើយ។ ទ្រង់មានគ្រប់ អំណាច បញ្ញាញាណ និងការច្នៃប្រឌិត។

១. នៅដើមជំពូកដំបូងនៃព្រះគម្ពីរទាំងមូលបានចែងថា ព្រះជាម្ចាស់បានបង្កើតអ្វីៗទាំងអស់ ហើយមុនដែលទ្រង់បង្កើតអ្វីៗទាំងអស់ នោះគ្មានអ្វីសោះ។ សូមអានកណ្ឌគម្ពីរ លោកុប្បត្តិ ១:១-៥ ហើយកត់ចុះនូវចំណុចសំខាន់ៗមួយចំនួនដែលចែងពីការបង្កើតរបស់ទ្រង់ យ៉ាងហោចណាស់ឲ្យបានបីចំណុច។

២. តើព្រះជាម្ចាស់បានបង្កើតពិភពលោកដោយរបៀបណា? (ហេព្រើរ ១១:៣)

៣. តើព្រះជាម្ចាស់បានតុបតែង ហើយបង្កើតរូបលោកអ្នកចេញមកពីព្រះបញ្ញាញាណ និងឫទ្ធានុភាពដ៏គ្មានដែនកំណត់របស់ទ្រង់នោះដើម្បីអ្វី? (អេសាយ ៤៣:៧)

៤. សេចក្តីថ្លៃថ្នូរដែលព្រះជាម្ចាស់ប្រទានដល់មនុស្ស បានបង្ហាញចេញតាមរយៈលក្ខណៈពិសេស អំណាច និងបំណងរបស់មនុស្ស។ សូមសរសេរចុះពីគំនិតមួយចំនួនចេញពី កណ្ឌគម្ពីរ លោកុប្បត្តិ ១:២៦-២៨ ដែលបង្ហាញពី៖

ក) លក្ខណៈពិសេសរបស់មនុស្ស

ខ) តំណែង ឬអំណាចរបស់មនុស្ស

គ) គោលបំណងរបស់ព្រះជាម្ចាស់ចំពោះមនុស្ស

៥. តើលោកអ្នកចូលចិត្តលក្ខណៈពិសេសដែលព្រះជាម្ចាស់បានប្រទានឲ្យក្នុងនាមជាមនុស្សដែរឬទេ? ហេតុអ្វីចូលចិត្ត ឬ ហេតុអ្វីមិនចូលចិត្ត?

៦. តើលោកអ្នកឆ្លើយតបចំពោះព្រះជាម្ចាស់ដែលជា ព្រះអាទិករ* របស់លោកអ្នកយ៉ាងដូចម្ដេច? (វិវរណៈ ៤:១១)

* **ព្រះអាទិករ** មានន័យថា ព្រះដែលបានបង្កើតអ្វីៗទាំងអស់

# ព្រះជាម្ចាស់គង់នៅគ្រប់ទីកន្លែង ហើយទ្រង់ស្គាល់លោកអ្នក



៧. នៅក្នុងកណ្ឌគម្ពីរ ទំនុកដំកើង ១៣៩:១-៨
ស្ដេច ដាវីឌ លើកឡើងពីចំណុចមួយចំនួនដែលព្រះជាម្ចាស់បាន «ពិនិត្យមើល ហើយនិងស្គាល់» ពីជីវិតរបស់ស្ដេច ដាវីឌ។ សូមសរសេរចុះពីចំណុចទាំងនោះយ៉ាងហោចណាស់ឲ្យបានបួនចំណុច។ បន្ទាប់មកសូមគូសគំនូសចំណាំទៅលើចំណុចដែលលោកអ្នកយល់ថា ព្រះជាម្ចាស់ជ្រាបពីជីវិតរបស់លោកអ្នក។

“ *ព្រះគុណមានន័យថា មិនមានអ្វីដែលខ្ញុំអាចធ្វើ ដើម្បីឲ្យព្រះជាម្ចាស់កាន់តែស្រឡាញ់ខ្ញុំជាងមុននោះទេ ហើយក៏មិនមានអ្វីដែលខ្ញុំអាចធ្វើ ដើម្បីឲ្យព្រះជាម្ចាស់ស្រឡាញ់ខ្ញុំតិចជាងមុននោះដែរ។ ព្រះគុណមានន័យថា ទោះបីជាខ្ញុំស័ក្តិសមទទួលអ្វីដែលផ្ទុយពីព្រះគុណក៏ដោយ ក៏ព្រះជាម្ចាស់អញ្ជើញខ្ញុំឲ្យមកនៅកន្លែងដែលទ្រង់បានរៀបចំឲ្យខ្ញុំនៅក្នុងក្រុមគ្រួសាររបស់ព្រះជាម្ចាស់ដែរ។*

លោក ភីលីព យែនស៊ី (Philip Yancey)
ដកស្រង់ចេញពីសៀវភៅ *What's So Amazing About Grace?*

៨. តើស្ដេច ដាវីឌ បានឆ្លើយតបទៅព្រះជាម្ចាស់វិញយ៉ាងដូចម្ដេច នៅពេលដែលទ្រង់ទទួលស្គាល់ថា ព្រះជាម្ចាស់ជ្រាបពីទ្រង់យ៉ាងច្បាស់ ហើយដឹងថាព្រះជាម្ចាស់មានវត្តមាននៅគ្រប់ទីកន្លែង?
(ទំនុកដំកើង ១៣៩:២៣-២៤)

៩. តើលោកអ្នកមានអារម្មណ៍យ៉ាងដូចម្ដេច ចំពោះចំណាប់អារម្មណ៍ដែលព្រះជាម្ចាស់បានរៀបរាប់ពីលោកអ្នក ដូចដែលព្រះយេស៊ូវបានមានបន្ទូលនៅក្នុងកណ្ឌគម្ពីរ ម៉ាថាយ ១០:២៩-៣១?

# ព្រះជាម្ចាស់ស្រឡាញ់លោកអ្នក



១០. តើការបង្ហាញដ៏ធំធេងបំផុតពីសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់គឺជាអ្វី? (១យ៉ូហាន ៤:៩-១០)

## ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក...

**អស់អ្នកណាដែលជឿដល់ទ្រង់**

ប៉ុន្តែឲ្យមាន

មិនត្រូវវិនាសឡើយ

ជីវិតអស់កល្បជានិច្ចវិញ

**ស្លាប់ ⟶ ជីវិត**

**ទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែមួយ**

១១. សូមសិក្សាពីកណ្ឌគម្ពីរ យ៉ូហាន ៣:១៦ ដែលទាក់ទងទៅនឹងគំនូសតាង នៅទំព័រ១៥។

ក) តើមានអ្វីដែលបានជំរុញព្រះទ័យរបស់ព្រះជាម្ចាស់ឲ្យលះបង់ព្រះរាជបុត្រាទ្រង់សម្រាប់យើងរាល់គ្នា?

ខ) តើបុគ្គលម្នាក់អាចឆ្លើយតបទៅនឹងការប្រទាននូវជីវិតអស់កល្បជានិច្ច របស់ព្រះជាម្ចាស់យ៉ាងដូចម្ដេច?

> *“ព្រះយេស៊ូវ គឺជាទ្វារទៅកាន់ជីវិតដែលជាជីវិតដ៏ពិត។ ហើយដោយសារយើងទុកចិត្តលើទ្រង់ នោះបណ្ដាលឲ្យយើងក្លាយជាសិស្សរបស់ទ្រង់ ដើម្បីរៀនពីរបៀបរស់នៅអស់កល្បជានិច្ច ដូចដែលអ្នកសំណព្វរបស់ព្រះជាម្ចាស់បានធ្វើនៅសម័យមុន។ ទ្រង់មានបន្ទូលថា “អ្នកណាចូលតាមខ្ញុំ នោះនឹងបានសង្គ្រោះ រួចនឹងចេញចូល ហើយនឹងរកបានវាលស្មៅដ៏ស្រួល។*

*...ខ្ញុំបានមក ដើម្បីឲ្យវារាល់គ្នាមានជីវិត ហើយឲ្យមានជីវិតនោះពេញបរិបូរណ៍ផង»។*

លោក ដាលទ្បាស វើលទ្បាឌ (Dallas Willard)
ដកស្រង់ចេញពីសៀវភៅ *The Divine Conspiracy*

១២. នៅក្នុងកណ្ឌគម្ពីរ យ៉ូហាន ១០:៩-១៦ ព្រះយេស៊ូវបានប្រៀបធៀបសេចក្តីស្រឡាញ់ និងការយកចិត្តទុកដាក់របស់ទ្រង់ដូចទៅនឹងអ្នកគង្វាលចៀមដែលស្រឡាញ់ និងយកចិត្តទុកដាក់ចំពោះកូនចៀមខ្លួន។ យោងទៅតាមអត្ថបទខាងលើនេះ តើព្រះយេស៊ូវយកព្រះទ័យទុកដាក់ចំពោះយើងរាល់គ្នាតាមរបៀបណាខ្លះ?

១៣. តើលោកអ្នកមានអារម្មណ៍ថា លោកអ្នកស័ក្តិសមនឹងទទួលសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ដែរឬទេ? តើការព្រមទទួលយកសេចក្តីស្រឡាញ់ងាយស្រួលចំពោះលោកអ្នកដែរឬទេ? ហេតុអ្វីបានជាងាយស្រួល ឬហេតុអ្វីបានជាមិនងាយស្រួល?

១៤. តើលោកអ្នកគិតថា លោកអ្នកត្រូវតែក្លាយជាមនុស្សដែលស័ក្តិសមនឹងទទួលសេចក្តីស្រឡាញ់ មុននឹងទ្រង់ស្រឡាញ់លោកអ្នកឬ?
សូមពន្យល់៖

## ផ្អាកបន្តិចដើម្បីអធិស្ឋាន

សូមអរព្រះគុណដល់ព្រះជាម្ចាស់ចំពោះគ្រប់ទាំងសេចក្តីដែលលោកអ្នកបានសរសេរចុះនៅក្នុងសំណួរទី១២។ សូមសរសើរតម្កើងព្រះអង្គដែលទ្រង់បានប្រទានគ្រប់ទាំងសេចក្តីនេះមកដល់លោកអ្នក ដោយព្រោះតែព្រះយេស៊ូវ ហើយមិនមែនដោយការប្រព្រឹត្តរបស់លោកអ្នកនោះទេ។

# ព្រះជាម្ចាស់បានយកលោកអ្នកមកធ្វើជាបុត្រចិញ្ចឹមនៅក្នុងគ្រួសាររបស់ទ្រង់

១៥. តើលោកអ្នកមានអារម្មណ៍យ៉ាងណា ពីការដែលលោកអ្នកហៅព្រះជាម្ចាស់ថាជាព្រះវរបិតា ដូចដែលព្រះយេស៊ូវបានបញ្ជាក់នៅក្នុងកណ្ឌគម្ពីរម៉ាថាយ ៦:៩?

១៦. តើវាជាការពិតដែរឬទេដែលថា ព្រះជាម្ចាស់ជាព្រះវរបិតានៃមនុស្សគ្រប់គ្នា? ហេតុអ្វីបានជាពិត ឬ ហេតុអ្វីបានជាមិនពិត? (យ៉ូហាន ៨:៤២-៤៤)

១៧. តើមនុស្សម្នាក់អាចកើតនៅក្នុងគ្រួសាររបស់ព្រះជាម្ចាស់បានដោយរបៀបណា? (យ៉ូហាន ១:១២-១៣)




*សារៈសំខាន់នៃការធានារ៉ាប់រងពីជំនឿស្ថិតនៅត្រង់ថា ខ្ញុំក៏ដូចកូនក្មេងតូចៗដែរ គឺមិនអាចស្រឡាញ់ ឬបម្រើព្រះជាម្ចាស់នោះទេ ប្រសិនបើខ្ញុំមិនដឹងថា ព្រះជាម្ចាស់ស្រឡាញ់ ហើយទទួលស្គាល់ខ្ញុំជាកូនរបស់ទ្រង់ ឬក៏អត់នោះ។*

លោក អាន់ឌ្រូ មឺរេយ (Andrew Murray)
ដកស្រង់ចេញពីសៀវភៅ *The New Life*

១៨. យោងតាមកណ្ឌគម្ពីរ រ៉ូម ៨:១៥-១៧ តើព្រះពរនៃការធ្វើជាកូនចិញ្ចឹមដ៏ពិតរបស់ព្រះជាម្ចាស់មានអ្វីខ្លះ? បន្ទាប់មកសូមគូសរង្វង់ទៅលើព្រះពរមួយណាដែលប៉ះពាល់ចិត្តលោកអ្នកជាងគេបំផុត នៅក្នុងចម្លើយរបស់លោកអ្នក។

សូមបំពេញឃ្លាប្រៀបធៀបខាងក្រោមនេះ៖

*ការចាប់កំណើតនៅក្នុងគ្រួសាររបស់ព្រះជាម្ចាស់ប្រៀបបានទៅនឹង...*

១៩. តើលោកអ្នកស្គាល់ព្រះជាម្ចាស់ថា ជាព្រះវរបិតារបស់លោកអ្នកបាន យ៉ាងច្បាស់ ឬក៏មិនទាន់ច្បាស់? សូមពណ៌នាខ្លីៗ៖




វាជាការសំខាន់ណាស់ក្នុងនាមជាអ្នកដើរតាមព្រះយេស៊ូវម្នាក់។ លោកអ្នកត្រូវតែដឹងឲ្យច្បាស់ថា ព្រះជាម្ចាស់គឺជាព្រះវរបិតារបស់លោកអ្នក ហើយក៏ត្រូវដឹងថាលោកអ្នកមានជីវិតអស់កល្បជានិច្ច។ ទោះបីជាអារម្មណ៍គឺជាចំណុចសំខាន់ក្នុងទំនាក់ទំនងគ្រប់ទាំងកាលៈទេសៈយ៉ាងណាក៏ដោយ ក៏អារម្មណ៍ទាំងនោះវាអាចផ្លាស់ប្តូរបានដោយហេតុផលផ្សេងៗជាច្រើន។ ហេតុដូច្នេះហើយ ការធានារ៉ាប់រងរបស់យើងរាល់គ្នាក្នុងនាមជាសមាជិកក្នុងគ្រួសាររបស់ព្រះជាម្ចាស់ដាច់ខាតត្រូវតែពឹងផ្អែកលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលទ្រង់ស្មោះត្រង់ ហើយរក្សាសេចក្តីសន្យារបស់ទ្រង់ជារៀងរហូត។ «ខ្ញុំបានសរសេរសេចក្តីទាំងនេះ ផ្ញើមកអ្នករាល់គ្នាដែលជឿដល់ព្រះនាមព្រះរាជបុត្រានៃព្រះ ដើម្បីឲ្យអ្នករាល់គ្នាបានដឹងថា អ្នករាល់គ្នាមានជីវិតអស់កល្បជានិច្ចហើយ» (១យ៉ូហាន ៥:១៣)។

ខគម្ពីរទាំងប៉ុន្មានខាងក្រោមនេះបានជួយមនុស្សជាច្រើន ដើម្បីទទួលយកនូវការធានារ៉ាប់រងនៃជីវិតដ៏អស់កល្បជានិច្ច។ ជាការល្អប្រសិនបើលោកអ្នកទន្ទេញខគម្ពីរណាមួយខាងក្រោមនេះឲ្យចាំ ដើម្បីនឹងពង្រឹងការធានារ៉ាប់រងរបស់លោកអ្នកឲ្យបានរឹងមាំឡើង។

“ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នកណាដែលស្តាប់ពាក្យខ្ញុំ ហើយជឿដល់ព្រះអង្គ ដែលចាត់ឲ្យខ្ញុំមក អ្នកនោះមានជីវិតដ៏នៅអស់កល្បជានិច្ច ហើយមិនដែលត្រូវជំនុំជំរះឡើយ គឺបានកន្លងហួសពីសេចក្តីស្លាប់ ទៅដល់ជីវិតវិញ» (យ៉ូហាន ៥:២៤)។

នេះហើយជាសេចក្តីបន្ទាល់នោះ គឺថា ព្រះទ្រង់បានប្រទានជីវិតដ៏នៅអស់កល្បជានិច្ចមកយើងរាល់គ្នា ហើយជីវិតនោះ គឺនៅក្នុងព្រះរាជបុត្រានៃទ្រង់ ឯអ្នកណាដែលមានព្រះរាជបុត្រា នោះក៏មានជីវិតដែរ តែអ្នកណាដែលគ្មានព្រះរាជបុត្រានៃព្រះទេ នោះគ្មានជីវិតឡើយ
(១យ៉ូហាន ៥:១១-១២)។

“មើល អញឈរនៅមាត់ទ្វារទាំងគោះ បើអ្នកណាឮសំឡេងអញ ហើយបើកទ្វារឲ្យ នោះអញនឹងចូលទៅឯអ្នកនោះ អញនឹងបរិភោគជាមួយនឹងអ្នកនោះ ហើយអ្នកនោះជាមួយនឹងអញដែរ»
(វិវរណៈ ៣:២០)។

# សៀវភៅកំណត់ហេតុរបស់ខ្ញុំ

សូមចងចាំថា លោកអ្នកមានឱកាសប្រើចន្លោះខាងក្រោមនេះ ដើម្បីសរសេរចុះនូវគំនិត និងអារម្មណ៍របស់លោកអ្នក។ សូមធ្វើការនេះតាមការយល់ឃើញរបស់លោកអ្នកដូចជា៖ **សរសេរសំណួរ**ដែលលោកអ្នកនៅតែមានចម្ងល់នៅក្នុងចិត្ត **សរសេរចម្លើយ**ដែលមានសារៈសំខាន់ចំពោះលោកអ្នក ព្រមទាំង**សង្ខេបគំនិត** និងអារម្មណ៍របស់លោកអ្នកទាំងអស់នៅក្នុងជំពូកនេះ ឬក៏**បង្កើតនូវគំនិតច្នៃប្រឌិត** ដូចជា៖ តែងកំណាព្យ គូរគំនូរ ជាដើម។ល។

## ចំណុចគួរចងចាំ

- ព្រះជាម្ចាស់បានបង្កើតលោកអ្នកតាមបំណងព្រះហឫទ័យរបស់ទ្រង់ និងដើម្បីថ្វាយសិរីល្អដល់ទ្រង់។ ទ្រង់បានប្រទានសេចក្តីថ្លៃថ្នូរដល់លោកអ្នកដោយបង្កើតលោកអ្នកឲ្យដូចជារូបអង្គទ្រង់។

- ព្រះជាម្ចាស់រាប់លោកអ្នកថាជាមនុស្សមានតម្លៃយ៉ាងខ្លាំង។ ព្រះវរបិតានៃយើងដែលមានព្រះវត្តមានគ្រប់ទីកន្លែង ទ្រង់យកព្រះទ័យទុកដាក់ក្នុងការស្គាល់លោកអ្នកយ៉ាងច្បាស់លាស់ដោយផ្ទាល់។

- ព្រះជាម្ចាស់ស្រឡាញ់លោកអ្នកយ៉ាងខ្លាំង ហេតុដូច្នេះហើយបានទ្រង់ប្រទានព្រះរាជបុត្រារបស់ទ្រង់មកសុគតនៅលើឈើឆ្កាងជំនួសអំពើបាបរបស់លោកអ្នក។ ការបើកបង្ហាញនូវសេចក្តីស្រឡាញ់របស់ទ្រង់នេះគឺបញ្ជាក់ឲ្យឃើញថា ទ្រង់សព្វព្រះហឫទ័យប្រទាននូវជីវិតអស់កល្ប និងជីវិតដ៏ពេញបរិបូរណ៍ដល់លោកអ្នក។

- នៅពេលដែលព្រះជាម្ចាស់បានប្រទានជីវិតនេះឲ្យដល់លោកអ្នកនៅក្នុងអង្គព្រះយេស៊ូវគ្រីស្ទ នោះលោកអ្នកបានកើតក្នុងគ្រួសាររបស់ព្រះជាម្ចាស់ខាងឯព្រលឹងវិញ្ញាណ។ ព្រះជាម្ចាស់ជាព្រះវរបិតារបស់លោកអ្នក។ លោកអ្នកគឺជាបុត្ររបស់ទ្រង់។ ទ្រង់យកព្រះហឫទ័យទុកដាក់ចំពោះលោកអ្នក!

*“ព្រះជាម្ចាស់ដៅចំណាំលោកអ្នក ហើយមិនអាចឈប់ខ្វល់ព្រះទ័យចំពោះលោកអ្នកនោះឡើយ។ មិនថាជាលោកអ្នកគិតថា ខ្លួនលោកអ្នកអាក្រក់ប៉ុណ្ណានោះទេ ព្រះជាម្ចាស់គឺនៅតែជាប់ចិត្តស្រឡាញ់លោកអ្នកដដែល។ មានពួកយើងដែលជាអ្នកជឿមួយចំនួនភ័យខ្លាចថា ថ្ងៃណាមួយពេលដែលយើងនឹងឆ្លោយប្រព្រឹត្តការដ៏អាក្រក់បំផុត នោះទ្រង់នឹងមិនដៅចំណាំយើងទៀតឡើយ។ សូមស្តាប់ខ្ញុំបន្តិច ព្រះជាម្ចាស់ស្រឡាញ់លោកអ្នកយ៉ាងពេញលេញ...ហើយនៅក្នុងសេចក្តីស្រឡាញ់របស់ទ្រង់ មិនមានលក្ខខណ្ឌអ្វីនោះទេ គឺមានតែសេចក្តីស្រឡាញ់ប៉ុណ្ណោះ។*

លោក រីច ម៉ូលលីនស៍ (Rich Mullins)

# ការចូលឲ្យបានស៊ីជម្រៅ

តើឪពុករបស់លោកអ្នកនៅផែនដីនេះមានលក្ខណៈយ៉ាងដូចម្ដេច? តើលោកអ្នកចូលចិត្តគាត់ដែរឬទេ? សូមពន្យល់៖

តើព្រះវរបិតាដ៏គ្រប់លក្ខណ៍ដែលគង់នៅស្ថានសួគ៌របស់យើងមានលក្ខណៈដូចម្ដេចដែរ? តើលោកអ្នកចូលចិត្តទ្រង់ដល់កម្រិតណា?



តើលោកអ្នកយល់ថា អារម្មណ៍ដែលលោកអ្នកមានចំពោះឪពុកដែលនៅលោកីយ៍នេះ មានផលប៉ះពាល់ទៅលើអារម្មណ៍ដែលលោកអ្នកមាន ចំពោះព្រះវរបិតារបស់លោកអ្នក ដែលគង់នៅស្ថានសួគ៌យ៉ាងដូចម្ដេចដែរ? សូមពន្យល់៖

ជំពូកទី

# ២

# បុគ្គលភាពនៃ ព្រះយេស៊ូវគ្រីស្ទ

មនុស្សលោកយើងនេះមិនមានលទ្ធភាពស្វែងយល់ពីព្រះជាម្ចាស់យ៉ាងពេញលេញបានឡើយ។ ព្រះជាម្ចាស់បរិសុទ្ធ ហើយល្អឥតខ្ចោះ ចំណែកឯមនុស្សវិញគឺមានបាប ហើយខ្វះសីលធម៌។ ដើម្បីចងមេត្រីភាពរវាងព្រះជាម្ចាស់ និងមនុស្សវិញ ទ្រង់បានយាងមកយកកំណើតជាមនុស្សគឺអង្គព្រះយេស៊ូវគ្រីស្ទ។

ព្រះយេស៊ូវគ្រីស្ទគឺជា «...រូបអង្គនៃព្រះដ៏មើលមិនឃើញ...ដ្បិតព្រះបានសព្វព្រះហឫទ័យឲ្យគ្រប់ទាំងសេចក្តីពោរពេញបានស្ថិតនៅក្នុងទ្រង់» (កូល៉ុស ១:១៥, ១៩)។ ដើម្បីបង្ហាញពីភាពជាព្រះជាម្ចាស់ដ៏ពេញលេញនោះ ព្រះយេស៊ូវគ្រីស្ទត្រូវតែមានភាពជាព្រះ។ ដើម្បីឲ្យមនុស្សបានឃើញ ហើយយល់ពីព្រះគ្រីស្ទយ៉ាងជាក់ច្បាស់នោះ ទ្រង់ត្រូវតែយាងមកយកកំណើតជាមនុស្ស។

ព្រះយេស៊ូវគ្រីស្ទមានលក្ខណៈពីរយ៉ាង គឺជាព្រះផង និងជាមនុស្សផង។

ដើម្បីឲ្យយើងងាយយល់ពីព្រះយេស៊ូវ យើងចាំបាច់ត្រូវតែស្វែងយល់ពីភាពជាព្រះ និងភាពជាមនុស្សរបស់ទ្រង់សិន។

## ភាពជាព្រះរបស់ព្រះយេស៊ូវគ្រីស្ទ



តើព្រះយេស៊ូវគ្រាន់តែជាមនុស្សដ៏អស្ចារ្យម្នាក់តែប៉ុណ្ណោះឬ? ចំពោះការយល់ឃើញរបស់មនុស្សមួយចំនួនគេយល់ឃើញថា ទ្រង់គឺគ្រាន់តែជាមេសាសនាថ្មីម្នាក់ប៉ុណ្ណោះ។ ហើយមានអ្នកខ្លះទៀតយល់ថា ទ្រង់គឺជាហោរាណាមួយ។ ប៉ុន្តែព្រះយេស៊ូវផ្ទាល់បានប្រកាសពីខ្លួនព្រះអង្គថា ទ្រង់គឺជាព្រះជាម្ចាស់។

ទ្រង់ក៏បានបញ្ជាក់អះអាងយ៉ាងច្បាស់ថា ទ្រង់គឺជាព្រះជាម្ចាស់។ ប្រសិនបើការប្រកាសរបស់ព្រះយេស៊ូវមិនមែនជាការពិតទេនោះ យើងក៏មិនអាចហៅទ្រង់ថាជាមនុស្សល្អបានដែរ តែឈ្មោះថា ទ្រង់ជាអ្នកបោកប្រាស់ និងជាអ្នកកុហកវិញ។

១. អ្នកនិពន្ធកណ្ឌគម្ពីរ ហេព្រើរបានពន្យល់បកស្រាយពីភាពជាព្រះរបស់ព្រះគ្រីស្ទនៅក្នុងជំពូកទី១។ សូមអានកណ្ឌគម្ពីរ ហេព្រើរ ១ មុននឹងលោកអ្នកឆ្លើយសំណួរទី១-៤។ តាមរយៈខគម្ពីរខាងក្រោមនេះ យើងអាចយល់ឃើញពីភាពដ៏វិសេសវិសាលរបស់ព្រះយេស៊ូវខ្ពង់ខ្ពស់ជាងពួកទេវតាដោយសារៈ

ខ៤-៥

ខ៦

ខ១៣-១៤

២. សូមអានកណ្ឌគម្ពីរ ហេព្រើរ ១:៨-១២ ម្ដងទៀត។ បន្ទាប់មកសូមសរសេរលេខខគម្ពីរ ដែលទាក់ទងទៅនឹងសេចក្ដីពិតនីមួយៗ នៅចន្លោះខាងក្រោមនេះឲ្យបានត្រឹមត្រូវ៖

ព្រះយេស៊ូវគឺជាព្រះអាទិករ ______________________________

ព្រះយេស៊ូវគឺជាព្រះដែលមិនប្រែប្រួល ______________________

ព្រះយេស៊ូវគឺជាព្រះដែលស្ថិតនៅអស់កល្បជានិច្ច ______________

ព្រះយេស៊ូវគឺជាព្រះដែលសុចរិត __________________________

៣. យោងតាមកណ្ឌគម្ពីរ ហេព្រើរ ១:៣ តើមានចំណុចណាខ្លះ ដែលលើកទឹកចិត្តលោកអ្នក ទាក់ទងទៅនឹងសមត្ថភាពរបស់ព្រះយេស៊ូវក្នុងការបើកបង្ហាញពីព្រះជាម្ចាស់?

៤. តើព្រះជាម្ចាស់មានព្រះតម្រិះពីព្រះយេស៊ូវនៅក្នុងកណ្ឌគម្ពីរ ហេព្រើរ ១:៨ និង ១:១០ យ៉ាងដូចម្ដេចខ្លះ?



៥. យោងតាមកណ្ឌគម្ពីរ យ៉ូហាន ១០:២៧-៣០ តើព្រះយេស៊ូវសន្យាអ្វី ចំពោះអស់អ្នកដែលដើរតាមទ្រង់? តើសេចក្តីសន្យានោះធ្វើឲ្យលោកអ្នក មានអារម្មណ៍យ៉ាងដូចម្តេច?

៦. នៅពេលដែលព្រះយេស៊ូវគង់នៅផែនដី ទ្រង់បានធ្វើការអស្ចារ្យជាច្រើនដែល បានបង្ហាញយើងឲ្យឃើញយ៉ាងច្បាស់ពីភាពជាព្រះដ៏មានព្រះចេស្តារបស់ ទ្រង់។ សូមសរសេរចុះពីរបៀបដែលព្រះយេស៊ូវបានបង្ហាញពីព្រះចេស្តា របស់ទ្រង់ ចេញពីខគម្ពីរមួយចំនួននៃកណ្ឌគម្ពីរ ម៉ាថាយ ៨ ខាងក្រោម ដូចតទៅ៖

ខ៣

ខ៦ និង ១៣

ខ១៦-១៧

ខ២៣-២៧

៧. សូមស្រមៃមើលថា លោកអ្នកកំពុងនៅក្នុងសម័យព្រះយេស៊ូវ ហើយឃើញទ្រង់សម្តែងការអស្ចារ្យទាំងអស់នោះ។ តើលោកអ្នកនឹងរៀបរាប់ប្រាប់មិត្រភក្តិរបស់លោកអ្នកពីអ្វីដែលបានកើតឡើងនោះយ៉ាងដូចម្តេច?



៨. សូមអានកណ្ឌគម្ពីរ យ៉ូហាន ១១:៣៨-៤៤។ តើលោកអ្នកយល់ថា ការបង្ហូរអំណាចរបស់ព្រះយេស៊ូវដែលគ្មានអ្វីប្រៀបបាននោះ បានប៉ះពាល់ដល់អស់អ្នកដែលនៅទីនោះយ៉ាងដូចម្ដេចខ្លះ?

៩. បន្ទាប់ពីសាវ័ក ពេត្រុស បានសង្កេតអំពីជីវិត អំណាច និងការបង្រៀនរបស់ព្រះគ្រីស្ទហើយ តើសាវ័ក ពេត្រុស បានសន្និដ្ឋានយ៉ាងដូចម្ដេចខ្លះអំពីទ្រង់? (ម៉ាថាយ ១៦:១៣-១៦)

ហើយបន្ទាប់មកគាត់បានសន្និដ្ឋានយ៉ាងដូចម្ដេចនៅក្នុងកណ្ឌគម្ពីរកិច្ចការ ៤:១២?

១០. ព្រះយេស៊ូវបានយកកំណើត បានរស់នៅ បានសុគត ហើយបានរស់ឡើងវិញពីសេចក្តីស្លាប់ រួចទ្រង់ក៏បានយាងឡើងទៅស្ថានសួគ៌វិញ។ ប៉ុន្តែ ចុះតើទ្រង់កំពុងធ្វើអ្វីខ្លះសព្វថ្ងៃនេះ និងនៅថ្ងៃអនាគត? សូមពិចារណាខគម្ពីរខាងក្រោមនេះ ស្របពេលដែលលោកអ្នកសញ្ជឹងគិតពីព្រះយេស៊ូវនាពេលបច្ចុប្បន្ន។

រ៉ូម ៨:៣៤

ភីលីព ២:៩-១១

វិវរណៈ ៥:១១-១២

១១. សូមរំឭកសំណួរទី ១-១០ ឡើងវិញ។ ចូរផ្តល់ហេតុផលឲ្យបានបីដែលបញ្ជាក់ថា លោកអ្នកជឿថាព្រះយេស៊ូវជាព្រះជាម្ចាស់។

# ភាពជាមនុស្សរបស់ព្រះយេស៊ូវគ្រីស្ទ



១២. តើភាពជាមនុស្សរបស់ព្រះយេស៊ូវបានស្ដែងចេញឡើងតាមស្ថានភាពខាងក្រោមយ៉ាងដូចម្ដេចខ្លះ?

យ៉ូហាន ៤:៦

យ៉ូហាន ៤:៧

យ៉ូហាន ១១:៣៥

# ទំនាយអំពីព្រះយេស៊ូវគ្រីស្ទ

ដោយសារព្រះយេស៊ូវបានបំពេញនូវទំនាយ នោះជួយយើងឲ្យយល់ច្បាស់ថាព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះជាម្ចាស់។ ទោះបីហោរាបានទាយពីទំនាយទាំងនេះមុនព្រះយេស៊ូវយាងមករាប់រយឆ្នាំក៏ដោយ ព្រះយេស៊ូវបានបំពេញគ្រប់ទាំងបទទំនាយទាំងនោះ ហើយការបំពេញនោះបង្ហាញឲ្យឃើញថា ការប្រកាសរបស់ព្រះយេស៊ូវគ្រីស្ទគឺជាការពិត។ តារាងខាងក្រោមនេះគឺជាតារាងសង្ខេបពីទំនាយខ្លះៗដែលទាក់ទងទៅនឹងព្រះគ្រីស្ទ និងរបៀបដែលព្រះយេស៊ូវបានបំពេញទំនាយទាំងនោះ។

| ប្រធានបទ | ទំនាយ | ការបំពេញទំនាយ |
|---|---|---|
| ទីកន្លែងកំណើត | “ដូច្នេះ អ្នកនោះនឹងប្រគល់គេទៅដរាបដល់កំណត់នៃនាងដែលឈឺនឹងសំរាលបានកើតកូនមក នោះសំណល់នៃពួកបងប្អូនរបស់អ្នកនោះ នឹងបានវិលត្រឡប់មកឯពួកកូនចៅអ៊ីស្រាអែលវិញ” (មីកា ៥:២) ៧០០ មុន គ.ស។ | “កាលព្រះយេស៊ូវទ្រង់ប្រសូតមកនៅក្នុងភូមិបេថ្លេហិម ស្រុកយូដា...” (ម៉ាថាយ ២:១)។ |
| ប្រសូតពីស្ត្រីព្រហ្មចារី | “...មើលនាងព្រហ្មចារីនឹងមានគភ៌ ប្រសូតបានបុត្រា១ ហើយនឹងឲ្យព្រះនាមថា អេម៉ាញូអែល” (អេសាយ ៧:១៤) ៧០០ មុន គ.ស។ | “...គឺនាងម៉ារា មាតាទ្រង់ កាលដែលយ៉ូសែបបានដណ្តឹងនាងហើយ នោះនាងមានគភ៌ដោយព្រោះព្រះវិញ្ញាណបរិសុទ្ធ មុនដែលបាននៅជាមួយគ្នា” (ម៉ាថាយ ១:១៨)។ |
| ការចូលមកដល់នូវជ័យជម្នះរបស់ទ្រង់ | “ឱកូនស្រីស៊ីយ៉ូនអើយ ចូររីករាយជាខ្លាំងឡើង ឱកូនស្រីយេរូសាឡិមអើយ ចូរស្រែកហ៊ោចុះ មើល ស្តេចរបស់នាង ទ្រង់យាងមកឯនាង ទ្រង់ជាអ្នកសុចរិត ហើយមានជ័យជំនះ ទ្រង់ក៏សុភាព ទ្រង់គង់លើសត្វលា គឺជាលាជំទង់ ជាកូនរបស់មេលា” (សាការី ៩:៩) ៥០០ មុន គ.ស។ | “នោះមានគ្នាសន្ធឹក យកធាងចាកចេញទៅទទួលទ្រង់ ទាំងស្រែកថា ហូសាណា ព្រះអង្គដែលយាងមកដោយព្រះនាមព្រះអម្ចាស់ គឺជាស្តេចនៃសាសន៍អ៊ីស្រាអែល ទ្រង់ប្រកបដោយព្រះពរ កាលព្រះយេស៊ូវរកបានកូនលា១ នោះក៏គង់លើវា...” (យ៉ូហាន ១២:១៣-១៤)។ |

| | | |
|---|---|---|
| មិត្របានក្បត់ទ្រង់ | “អើ ទាំងមិត្រសំឡាញ់ស្និទ្ធស្នាលរបស់ទូលបង្គំ ជាអ្នកទូលបង្គំបានទុកចិត្ត ហើយក៏បានបរិភោគបាយរបស់ទូលបង្គំផង នោះបានលើកកែងជើងចង់ជាន់ឈ្លីទូលបង្គំដែរ” (ទំនុកដំកើង ៤១:៩) ១000 មុន គ.ស។ | “ឯយូដាស-អ៊ីស្ការីយ៉ុត ជាអ្នក១ក្នុងពួក១២ វាក៏ទៅឯពួកសង្គ្រាជ ដើម្បីនឹងបញ្ជូនទ្រង់ទៅគេ” (ម៉ាកុស ១៤:១០)។ |
| ទ្រង់ត្រូវគេបោះបង់ចោល | “ទ្រង់ត្រូវគេមើលងាយ ហើយត្រូវមនុស្សបោះបង់ចោល...ដូចជាអ្នកណាដែលមនុស្សគេចមុខចេញហើយយើងរាល់គ្នាមិនបានរាប់អានទ្រង់សោះ” (អេសាយ ៥៣:៣) ៧00 មុន គ.ស។ | “ទ្រង់បានយាងមកគង់នៅផែនដីរបស់ទ្រង់ តែរាស្ត្រទ្រង់មិនបានទទួលទ្រង់សោះ” (យ៉ូហាន ១:១១)។ |
| ជាប់ឆ្កាងជាមួយមនុស្សមានបាប | “...គេបានរាប់ទ្រង់ទុកជាអ្នកទទឹងច្បាប់...” (អេសាយ ៥៣:១២) ៧00 មុន គ.ស។ | “គេ...ក៏ឆ្កាងចោរ២នាក់ជាមួយនឹងទ្រង់ដែរ ១ខាងស្តាំ ហើយ១ខាងឆ្វេង” (ម៉ាថាយ ២៧:៣៦, ៣៨)។ |
| គេចាក់ទម្លុះដៃនិងជើងរបស់ទ្រង់ | “...គេបានចាក់ទំលុះដៃជើងនៃទូលបង្គំ” (ទំនុកដំកើង ២២:១៦) ១000 មុន គ.ស។ | “...ចូរលូកម្រាមដៃអ្នកមក ស្ទាបមើលដៃខ្ញុំឯណេះ ហើយលូកដៃមកក្នុងចំហៀងខ្ញុំផង...” (យ៉ូហាន ២0:២៧)។ |
| ការរស់ឡើងវិញរបស់ទ្រង់ | “ទ្រង់មិនទុកឲ្យព្រលឹងទូលបង្គំនៅក្នុងស្ថានឃុំព្រលឹងមនុស្សស្លាប់ទេ ក៏មិនព្រមឲ្យអ្នកបរិសុទ្ធរបស់ទ្រង់ឃើញសេចក្តីពុករលួយដែរ” (ទំនុកដំកើង ១៦:១០)<br>១000 មុន គ.ស។ | “អ្នករាល់គ្នាបានសំឡាប់ព្រះអម្ចាស់ជីវិតនោះទៅ តែព្រះបានប្រោសឲ្យទ្រង់មានព្រះជន្មរស់ពីស្លាប់ឡើងវិញ” (កិច្ចការ ៣:១៥)។ |
| ការយាងឡើងទៅស្ថានសួគ៌វិញ | “ទ្រង់បានយាងឡើងទៅឯស្ថានខ្ពស់...” (ទំនុកដំកើង ៦៨:១៨) ១000 មុន គ.ស។ | “...ព្រះបានលើកទ្រង់ឡើងទៅ រួចមានពពកមកបំបាំងទ្រង់ ពីភ្នែកគេ” (កិច្ចការ ១:៩)។ |

១៣. តារាងនៅទំព័រ ៣៨ និង ៣៩ បានបង្ហាញពីរបៀបដែលព្រះគ្រីស្ទបាន បំពេញតាមបទទំនាយ។ តើខគម្ពីរដែលនៅក្នុងតារាងនោះជះឥទ្ធិពល លើការយល់ឃើញរបស់លោកអ្នកដែលថា **ព្រះយេស៊ូវជានរណា** យ៉ាង ដូចម្ដេចខ្លះ?

១៤. នៅក្នុងកណ្ឌគម្ពីរ ម៉ាថាយ ៤:១-១១ មានចែងពីរឿងដែលព្រះយេស៊ូវបាន ប្រឈមមុខទៅនឹងសេចក្ដីល្បួង។

ក) ចម្លើយទាំងបីរបស់ព្រះយេស៊ូវទៅកាន់សាតាំងក្នុងរឿងនេះ គឺព្រះយេស៊ូវបានប្រើឃ្លាដូចៗគ្នា។

តើឃ្លានោះគឺជាឃ្លាអ្វី?

តើឃ្លានោះមានន័យដូចម្ដេច?

ខ) សូមផ្ទុផ្ទងខគម្ពីរ ម៉ាថាយដែលស៊ីគ្នានឹងខគម្ពីរ ចោទិយកថាខាងក្រោមនេះ៖

| | |
|---|---|
| ម៉ាថាយ ៤:៤ | ចោទិយកថា ៦:១៣ |
| ម៉ាថាយ ៤:៧ | ចោទិយកថា ៦:១៦ |
| ម៉ាថាយ ៤:១០ | ចោទិយកថា ៨:៣ |

គ) តើសេចក្តីល្បួងណាមួយដែលលោកអ្នកជួបប្រទះជារឿយៗ?

ឃ) តើលោកអ្នកអាចដើរតាមគំរូព្រះយេស៊ូវ ហើយប្រដាប់ខ្លួនលោកអ្នកដើម្បីទាស់ប្រឆាំងនឹងសេចក្តីល្បួងនេះយ៉ាងដូចម្តេច?

## ផ្អាកបន្តិចដើម្បីអធិស្ឋាន

- អរព្រះគុណព្រះជាម្ចាស់ដែលទ្រង់យល់ហើយស្គាល់ពីសេចក្ដីល្បួង។
- ទូលសូមព្រះជាម្ចាស់ឲ្យជួយលោកអ្នក ដើម្បីយកឈ្នះលើសេចក្ដីល្បួងនេះ។
- ពេលលោកអ្នកធ្លាក់ក្នុងសេចក្ដីល្បួង សូមនឹកចាំពីសេចក្ដីសន្យារបស់ទ្រង់ដែលថា “បើយើងលន់តួបាបវិញ នោះទ្រង់មានព្រះហឫទ័យស្មោះត្រង់ ហើយសុចរិត ប្រយោជន៍នឹងអត់ទោសបាបឲ្យយើង ហើយសំអាតយើង ពីគ្រប់អំពើទុច្ចរិតទាំងអស់ផង” (១យ៉ូហាន ១:៩)។
- អរព្រះគុណចំពោះសេចក្ដីមេត្តាករុណារបស់ទ្រង់។



១៥. សូមអានកណ្ឌគម្ពីរ ហេព្រើរ ៤:១៥-១៦។

ក) តើព្រះយេស៊ូវមានបទពិសោធន៍អ្វី ដែលមនុស្សតែងតែជួបប្រទះ?

(ខ១៥)

ខ) តើលោកអ្នកមានអារម្មណ៍យ៉ាងដូចម្តេច ពីការដែលព្រះយេស៊ូវទ្រង់ផ្ទាល់ស្គាល់នូវ ការឈឺចាប់ សេចក្តីល្បួង និងការរងទុក្ខលំបាករបស់លោកអ្នក ដោយសារទ្រង់ក៏ធ្លាប់បានឆ្លងកាត់រួចមកហើយដែរ? (ខ១៦)

គ) តើការចែកចាយនូវបទពិសោធន៍ពីភាពជាមនុស្សរបស់ព្រះយេស៊ូវជាមួយយើង មានអត្ថប្រយោជន៍យ៉ាងណាខ្លះ? (ខ១៦)

> “ *យើងត្រូវជ្រើសរើសថាតើ ព្រះយេស៊ូវជាព្រះរាជបុត្រានៃព្រះជាម្ចាស់ ឬជាមនុស្សឆ្កួត ឬក៏ជាមនុស្សដែលអាក្រក់ជាងនេះទៅទៀត។ កុំឲ្យយើងចេះតែបញ្ចើចបញ្ចើដោយមិនសមហេតុសមផលថា ទ្រង់គ្រាន់តែជាគ្រូល្អម្នាក់នោះ ដ្បិតព្រះយេស៊ូវមិនចង់ឲ្យយើងគិតយ៉ាងដូច្នេះទេ ព្រោះក្នុងជីវិតរបស់ទ្រង់ គ្មានកន្លែងណាមួយដែលបញ្ជាក់ថា ទ្រង់គ្រាន់តែជាគ្រូល្អម្នាក់នោះឡើយ។*
>
> លោក ស៊ី. អេស. ល្វីស (C. S. Lewis)

១៦. តើលោកអ្នកគិតថា ព្រះយេស៊ូវគឺជានរណា?

សូមគូសសញ្ញាគ្រីស (✓) នូវចម្លើយដែលលោកអ្នកយល់ថាត្រឹមត្រូវ

____ ជាមនុស្សល្អម្នាក់

____ ជាមនុស្សល្អ តែជាមនុស្សដែលស្លាប់បាត់ហើយ

____ ជាហោរាផង និងជាគ្រូម្នាក់ផង

____ ជាមនុស្សម្នាក់ដែលរស់ពីស្លាប់ឡើងវិញ

____ ជាមនុស្សម្នាក់ដែលដូចទៅនឹងព្រះ

____ ជាព្រះរាជបុត្រារបស់ព្រះ

____ ជាព្រះសង្គ្រោះនៃមនុស្សលោក

____ ជាអ្នកផ្ដើម ហើយក៏ជាអ្នកបញ្ចប់ជំនឿរបស់យើង

____ ជាបងប្អូនរបស់យើង

____ ផ្សេងៗ ________________________________

១៧. តើព្រះយេស៊ូវមានបន្ទូលយ៉ាងដូចម្ដេចដែលបញ្ជាក់ថា ទ្រង់ស្មើនឹងព្រះជាម្ចាស់គ្រប់បែបយ៉ាង?

| | |
|---|---|
| យ៉ូហាន ៥:១៩-២០ | មានព័ន្ធកិច្ចស្មើគ្នា |
| យ៉ូហាន ៥:២១, ២៨-២៩ | មានអំណាចក្នុងការប្រោសឲ្យរស់ឡើងវិញស្មើគ្នា |
| យ៉ូហាន ៥:២២, ២៧ | |
| យ៉ូហាន ៥:២៣ | |
| យ៉ូហាន ៥:២៤-២៥ | |
| យ៉ូហាន ៥:២៦ | មានព្រះជន្មគង់នៅស្មើគ្នា |

*“ព្រះយេស៊ូវយាងមកយកកំណើតជាមនុស្សក្នុងគោលបំណងតែមួយ គឺរៀបចំផ្លូវសម្រាប់នាំមនុស្សឲ្យត្រឡប់ទៅកាន់ព្រះជាម្ចាស់វិញ ដើម្បីឲ្យពួកគេឈរ នៅចំពោះព្រះភ័ក្ត្រទ្រង់ ក្នុងនាមជាមិត្រសម្លាញ់ ហើយជាអ្នកដែលស្រឡាញ់ព្រះជាម្ចាស់អស់ពីចិត្ត ដូចដែលទ្រង់មានបំណងចំពោះពួកគេតាំងពីដើមដំបូងមក។*

លោក អូស្វលដ៍ ឈេមប័រស៍ (Oswald Chambers)

១៨. តើលោកអ្នកមានសំណួរមន្ទិលសង្ស័យ ឬក៏បញ្ហាអ្វីខ្លះជាមួយព្រះយេស៊ូវ ដែលលោកអ្នកនៅតែមានបំណងចិត្តចង់ដោះស្រាយដែរឬទេ?

១៩. សូមអានកណ្ឌគម្ពីរ យ៉ូហាន ២០:២៤-២៩។ តើមានអ្វីខ្លះកើតឡើងចំពោះសាវ័ក ថូម៉ាស (ពេលខ្លះគេហៅគាត់ថា អ្នកសង្ស័យ) នៅពេលដែលគាត់បានឃើញព្រះយេស៊ូវបន្ទាប់ពីទ្រង់បានរស់ពីសុគតឡើងវិញ?

“ *ទោះបីយើងរស់នៅក្នុងលោកីយ៍ដែលមានគំនិតថា ការពិតឬមិនពិតអាចប្រែប្រួលទៅតាមកាលៈទេសៈយ៉ាងណាក៏ដោយ ក៏យើងបានឃើញថាមានសេចក្ដីពិតដ៏ជាក់លាក់មួយ ហើយសេចក្ដីពិតនោះ គឺជាព្រះយេស៊ូវ។ ព្រះយេស៊ូវមិនមែនត្រឹមតែផ្សាយដំណឹងល្អតែប៉ុណ្ណោះទេ តែទ្រង់ នោះហើយគឺជាដំណឹងល្អ។ សេចក្ដីពិតនេះមិនមែនជា ប្រព័ន្ធជំនឿរបស់សាសនា ឬក៏វិទ្យាស្ថានសាសនានោះទេ។ សេចក្ដីពិត គឺជាបុគ្គលម្នាក់។ យើងទទួលសេចក្ដីពិតតាមការជឿព្រះយេស៊ូវដែលទ្រង់ គឺជាអ្នកនិពន្ធនៃសេចក្ដីពិត។*

លោក យ៉ូណាថាន អេស ខេមប៊ែល ជាមួយ លោកស្រី ចេននីហ្វ័រ ខេមប៊ែល
(Jonathan S. Campbell with Jennifer Campbell)
ដកស្រង់ចេញពីសៀវភៅ *The Way of Jesus: A Journey of Freedom for Pilgrims and Wanderers*

# សៀវភៅកំណត់ហេតុរបស់ខ្ញុំ

តើឥឡូវនេះដំណើរនៃការសិក្សា និងការស្វែងយល់របស់លោកអ្នកពីព្រះគ្រីស្ទបានទៅដល់ចំណុចណាហើយ?

## ចំណុចគួរចងចាំ

- ព្រះយេស៊ូវគ្រីស្ទ គឺជារូបអង្គដ៏គ្រប់លក្ខណ៍នៃព្រះជាម្ចាស់។ ក្នុងនាមជាព្រះជាម្ចាស់ ព្រះយេស៊ូវមានអំណាចគ្រប់គ្រងលើផែនដី និងពួកទេវតាផងដែរ។

- ព្រះយេស៊ូវក៏ជាមនុស្សផងដែរ។ ទ្រង់មានបទពិសោធន៍ជាច្រើនដែលស្រដៀងទៅនឹងអ្វីដែលលោកអ្នកជួបប្រទះសព្វថ្ងៃនេះ។ ទ្រង់បានរងទុក្ខ ហើយជួបសេចក្តីល្បួង។ ទោះបីព្រះអង្គមិនដែលចាញ់សេចក្តីល្បួងក៏ដោយ ប៉ុន្តែការនេះធ្វើឲ្យទ្រង់យល់ ហើយមានសេចក្តីអាណិតអាសូរនៅពេលដែលលោកអ្នកជួបសេចក្តីល្បួង។ ពេលដែលលោកអ្នកធ្លាក់ក្នុងសេចក្តីល្បួង ព្រះជាម្ចាស់នឹងអត់ទោសឲ្យលោកអ្នក បើលោកអ្នកលន់តួបាបទៅកាន់ទ្រង់ (១យ៉ូហាន ១:៩)។

# ការចូលឲ្យបានស៊ីជម្រៅ

សូមសញ្ជឹងគិតទៅលើកណ្ឌគម្ពីរ ហេព្រើរ ២:១១។ តាមការយល់ឃើញរបស់លោកអ្នក ហេតុអ្វីបានជាព្រះយេស៊ូវមិនមានភាពអាម៉ាស់ឲ្យយើងចូលក្នុងគ្រួសាររបស់ទ្រង់? តើលោកអ្នកធ្លាប់មានអារម្មណ៍ថាអាម៉ាស់ចំពោះការធ្វើជាអ្នកដើរតាមព្រះយេស៊ូវដែរឬទេ? សូមពន្យល់៖

ព្រះយេស៊ូវបានមានបន្ទូលពីអង្គទ្រង់ផ្ទាល់ថា ទ្រង់ជាអ្នកដែលបំពេញតម្រូវការជាច្រើនរបស់មនុស្ស។ សូមពិចារណាទៅលើខគម្ពីរដែលមាននៅក្នុងតារាងខាងក្រោម។ តើលក្ខណៈព្រះយេស៊ូវដែលមានក្នុងខគម្ពីរទាំងនេះ មានន័យចំពោះជីវិតរបស់លោកអ្នកផ្ទាល់យ៉ាងដូចម្ដេច?

| ខយោង | របៀបដែលព្រះយេស៊ូវ ហៅខ្លួនព្រះអង្គផ្ទាល់ | អត្ថន័យចំពោះ ជីវិតលោកអ្នក |
|---|---|---|
| យ៉ូហាន ៤:១០-១៤ | ជាទឹករស់ | |
| យ៉ូហាន ៦:៣២-៣៥ | ជានំប៉័ងជីវិត | |
| យ៉ូហាន ៨:១២ | ជាពន្លឺលោកីយ៍ | |
| យ៉ូហាន ១០:៧-១០ | ជាទ្វារ | |

| | | |
|---|---|---|
| យ៉ូហាន ១០:១១-១៨ | ជាអ្នកគង្វាលល្អ | |
| យ៉ូហាន ១១:១៧-២៧, ៣២-៤៤ | ជាសេចក្ដីរស់ឡើងវិញ ហើយជាជីវិត | |
| យ៉ូហាន ១៤:១-៧ | ជាផ្លូវ ជាសេចក្ដីពិត ហើយជាជីវិត | |
| យ៉ូហាន ១៥:១-១៧ | ជាដើមទំពាំងបាយជូរដ៏ពិត | |

ជំពូកទី

# ៣

# ព័ន្ធកិច្ចរបស់ព្រះគ្រីស្ទ

មនុស្សជាច្រើនបានឮអំពីហេតុការណ៍ចុងក្រោយនៃជីវិតរបស់ព្រះយេស៊ូវនៅលើផែនដី ពេលខ្លះគេហៅថា ការរងទុក្ខរបស់ព្រះគ្រីស្ទ។ គេបានចោទប្រកាន់ទ្រង់ កាត់ក្តី ហើយនិងថ្កោលទោសដល់ជីវិតទ្រង់ដែលខុសពីការពិត។ បន្ទាប់មក ទ្រង់បានរងទុក្ខលំបាកប្រៀបដូចជាជនឧក្រិដ្ឋ ត្រូវគេឆ្កាងរហូតដល់ទីមរណា ហើយបីថ្ងៃក្រោយមក ទ្រង់មានព្រះជន្មរស់ឡើងវិញ។ ប៉ុន្តែមានមនុស្សតិចតួចដែលបានយល់ពីអត្ថន័យនៃហេតុការណ៍ទាំងនេះ។ នៅក្នុងជំពូកនេះ លោកអ្នកនឹងរៀនអំពី ជីវិត ការស្លាប់ និងការរស់ឡើងវិញរបស់ព្រះយេស៊ូវព្រមទាំងអត្ថន័យនៃហេតុការណ៍ទាំងអស់នេះ។

# ជីវិតរបស់ព្រះយេស៊ូវគ្រីស្ទ



ជាង២០០០ឆ្នាំមកហើយ ព្រះយេស៊ូវបានប្រសូត នៅក្នុងភូមិបេថ្លេហិម ដែលជាភូមិមិនសូវមាន ភាពឆើតឆាយប៉ុន្មានទេ។ កាលព្រះយេស៊ូវនៅជាទារកនៅឡើយ លោក យ៉ូសែប និងនាង ម៉ារា បាននាំទ្រង់ទៅឯប្រទេសអេហ្ស៊ីប ដើម្បីគេចពីសេចក្តីឃោរឃៅ នៃស្តេច ហេរ៉ូឌ។ បន្ទាប់មក ខណៈដែលទ្រង់នៅវ័យកុមារ ពួកគេបានទៅរស់ នៅឯភូមិណាសារ៉ែតក្នុងស្រុកកាលីឡេនៅប្រទេសអ៊ីស្រាអែល។

១. នៅពេលទេវតាបានប្រកាសពីកំណើតព្រះយេស៊ូវ តើទេវតានោះប្រាប់ពីគោលបំណងយ៉ាងណាចំពោះការយាងមកផែនដីរបស់ព្រះយេស៊ូវ? (ម៉ាថាយ ១:២១, លូកា ១:៣១-៣៣)

២. បន្ទាប់ពីធ្វើការជាមួយលោក យ៉ូសែប ដែលជាឪពុក និងជាជាងឈើរួចមក ទ្រង់ក៏បានចាប់ផ្តើមព័ន្ធកិច្ចរបស់ទ្រង់ជាសាធារណៈ ពេលដែលទ្រង់មានព្រះជន្ម៣០ព្រះវស្សា។ តើព័ន្ធកិច្ចជាសាធារណៈរបស់ព្រះយេស៊ូវមានអ្វីខ្លះ? (ម៉ាថាយ ៤:២៣)

៣. ព្រះយេស៊ូវមិនបានបំពេញបេសកកម្មទ្រង់តែអង្គឯងទេ។ យោងតាមកណ្ឌគម្ពីរ ម៉ាកុស ៣:១៤ តើបំណងព្រះហឫទ័យរបស់ទ្រង់ក្នុងការជ្រើសរើសមនុស្ស១២នាក់ឲ្យរស់នៅជាមួយទ្រង់ និងធ្វើព័ន្ធកិច្ចជាមួយនឹងទ្រង់គឺជាអ្វី? តើសាវ័កទាំង១២ មានបុគ្គលិកលក្ខណៈបែបណាខ្លះដែលបណ្តាលឲ្យព្រះគ្រីស្ទសព្វព្រះហឫទ័យនឹងជ្រើសរើសពួកគេ?

៤. សូមអានកណ្ឌគម្ពីរ លូកា ២២:២៥-២៧។ តើព្រះយេស៊ូវសព្វព្រះហឫទ័យឲ្យសិស្សរបស់ទ្រង់រស់នៅបែបណា?

ដើម្បីរស់នៅឲ្យត្រូវតាមបំណងព្រះហឫទ័យរបស់ព្រះយេស៊ូវ នាពេលសព្វថ្ងៃនេះ តើលោកអ្នកគួររស់នៅបែបណា?



៥. មុនពេលដែលគេបានឆ្កាងព្រះយេស៊ូវ ទ្រង់បានពង្រឹងទំនាក់ទំនងរបស់ទ្រង់ជាមួយនឹងពួកសិស្សឡើងវិញ។ ទ្រង់បានហៅពួកគេ ថាជាសម្លាញ់ (សូមអាន យ៉ូហាន ១៥:១៥)។ ស្របពេលដែលលោកអ្នកឆ្លុះបញ្ចាំង

អំពីជីវិតរបស់ព្រះយេស៊ូវ សូមគិតទៅមើលថា តើទ្រង់មានលក្ខណៈគួរឲ្យលោកអ្នកចង់ធ្វើជាមិត្ររបស់ទ្រង់ដែរឬទេ? តើលោកអ្នកមានបំណងចិត្តចង់ធ្វើជាមិត្ររបស់ទ្រង់នៅថ្ងៃនេះដែរឬទេ? សូមពន្យល់៖

ក្នុងមេរៀននេះយើងមិនមែនរៀនពីចំណុចទាំងអស់នៃជីវិតរបស់ព្រះយេស៊ូវគ្រីស្ទនោះទេ យើងគ្រាន់តែរៀនពីចំណុចខ្លះៗនៃជីវិតរបស់ទ្រង់តែប៉ុណ្ណោះ។ នៅខចុងក្រោយនៃកណ្ឌគម្ពីរ យ៉ូហាន សាវ័ក យ៉ូហាន បានសរសេរថា “មានការជាច្រើនទៀត ដែលព្រះយេស៊ូវបានធ្វើដែរ ខ្ញុំស្មានថា បើនឹងសរសេរទុកដោយលំដាប់តមក នោះលោកីយ៍ទាំងមូលក៏មិនល្មមគ្រាន់ ដើម្បីនឹងដាក់អស់ទាំងសៀវភៅ ដែលត្រូវសរសេរនោះផង» (យ៉ូហាន ២១:២៥)។ នៅទំព័រ៥៩ មានតារាងមួយដែលបញ្ជាក់ពីព្រឹត្តិការណ៍ដ៏សំខាន់ផ្សេងទៀតស្តីពីជីវិតរបស់ព្រះយេស៊ូវ។

# ការសុគតរបស់ព្រះយេស៊ូវគ្រីស្ទ



៦. ព្រះគម្ពីរសញ្ញាចាស់ និងព្រះយេស៊ូវផ្ទាល់បានទាយពីការសុគតរបស់ទ្រង់ (សូមអានលូកា ១៨:៣១-៣៣)។ សូមអានកណ្ឌគម្ពីរ ម៉ាថាយ ២៧:៣៤-៤៤។ សូមសង្ខេបខ្លីៗពីការសុគតរបស់ព្រះយេស៊ូវរួមជាមួយនឹងហេតុការណ៍ដែលបានកើតឡើងនៅជុំវិញទ្រង់ ហើយពិចារណាអំពីទុក្ខលំបាកដែលទ្រង់បានឆ្លងកាត់។

# ទិដ្ឋភាពទូទៅនៃជីវិតព្រះគ្រីស្ទ

| | ឆ្នាំនៃការលូតលាស់ | | ជាងឈើ | ព័ន្ធកិច្ចសាធារណៈ |
|---|---|---|---|---|

កំណើត — ២ — ១២ — ៣០ — ៣៣

**កំណើត:**
- កំណើតនៅភូមិបេថ្លេហិម
- ភៀសខ្លួនទៅប្រទេសអេហ្ស៊ីប
- ផ្ទះទីលំនៅទៅស្រុកកាលីឡេ

**១២:**
- ការយាងទៅលេងនៅព្រះវិហារ
- ការពិភាក្សាជាមួយពួកអាចារ្យ

## ការធ្វើព័ន្ធកិច្ចជាសាធារណៈក្នុងរយៈពេលបីឆ្នាំ

| ៣០ | ៣១ | ៣២ | ៣៣ |
|---|---|---|---|
| • ទទួលពិធីជ្រមុជទឹកដោយលោក យ៉ូហាន<br>• សាតាំងល្បួងនៅទីរហោស្ថាន<br>• ការអស្ចារ្យលើកទីមួយ គឺបានធ្វើទឹកឲ្យក្លាយជាស្រាទំពាំងបាយជូរ<br>• បុណ្យរំលងលើកទីមួយ ផ្ដាប់តុពួកអ្នកដូរលុយ<br>• ស្ត្រីនៅឯអណ្ដូងទឹក | • បុណ្យរំលងលើកទីពីរ<br>• ការត្រាស់ហៅពួកសាវ័កទាំង១២<br>• ការអធិប្បាយនៅលើភ្នំ<br>• រឿងប្រៀបប្រដូចទៅនឹងអ្នកព្រោះពូជ<br>• ការបណ្ដេញវិញ្ញាណអាក្រក់ដែលសណ្ឋិតនៅខ្លួនមនុស្សនៅស្រុកគេរ៉ាសីន | • មហាបេសកកម្មរបស់ពួកសាវ័កទាំង១២<br>• ការផ្ដត់ផ្គង់អាហារដល់មនុស្ស៥០០០នាក់<br>• ព្រះយេស៊ូវយាងកាត់លើទឹក<br>• ការប្រែព្រះកាយ<br>• បញ្ជូន៧០នាក់ទៅប្រកាសដំណឹងល្អ<br>• ការប្រោសឲ្យឡាសារស់ឡើងវិញ | សប្ដាហ៍ចុងក្រោយ |

## សប្ដាហ៍ចុងក្រោយ

| ការមកដល់ទីក្រុងយេរូសាឡិម | ថ្ងៃចុងបញ្ចប់នៃព័ន្ធកិច្ច | | ការជាប់ឆ្កាង | ការរស់ឡើងវិញ |
|---|---|---|---|---|
| • ការចូលដោយជ័យជម្នះក្នុងក្រុងយេរូសាឡិម<br>• បណ្ដេញពួកអ្នកដូរលុយចេញពីព្រះវិហារ | • បញ្ញត្តិដ៏សំខាន់ជាងគេៈ ស្រឡាញ់<br>• ទីសម្គាល់ពីអ្វីដែលនឹងកើតឡើងនាពេលអនាគត<br>• ផែនការក្បត់របស់សាសន៍យូដា និង សាវ័កយូដាស | • អាហារនៅថ្ងៃបុណ្យរំលង លាងជើងពួកសាវ័ក<br>• ពិធីលៀងព្រះអម្ចាស់<br>• គល់ដែលពិត<br>• ការអធិស្ឋានទូលអង្វរជំនួស<br>• ការក្បត់ | • ការកាត់ក្ដីនៅចំពោះពួកសម្ដេចសង្ឃ ក្រុមប្រឹក្សា លោកពីឡាត់ និងស្ដេច ហេរ៉ូឌ<br>• ការសុគតៈ ការឆ្កាង ការបញ្ចុះសព | • ការរស់ឡើងវិញ<br>• ការលេចមកឲ្យពួកសាវ័កឃើញ<br>• ការលេចមកឲ្យមនុស្ស៥០០នាក់ឃើញ<br>• ការយាងឡើងទៅស្ថានសួគ៌វិញ |

៧. យោងតាមកណ្ឌគម្ពីរ យ៉ូហាន ១០:១៧-១៨ តើព្រះយេស៊ូវបានយាងទៅឈើឆ្កាងដោយស្ម័គ្រព្រះទ័យឬ? សូមពន្យល់៖

៨. សូមអានកណ្ឌគម្ពីរ ១ពេត្រុស ៣:១៨ និងយ៉ូហាន ៣:១៨-១៩។ តាមការយល់ឃើញរបស់លោកអ្នក សូមគិតទៅមើលថា ហេតុអ្វីបានជាព្រះយេស៊ូវយាងមកសុគត?

> *សេចក្តីស្លាប់បានបាត់ទ្រនិចរបស់វា បន្ទាប់ពីវាបានទិចព្រះយេស៊ូវ ប្រៀបបាននឹងសត្វឃ្មុំដែលបាត់ទ្រនិចរបស់វា បន្ទាប់ពីវាបានទិចនរណាម្នាក់ហើយ។*
>
> លោក ដែននីស ស្តូខស៍ (Dennis Stokes)

៩. សូមអានកណ្ឌគម្ពីរ ១កូរិនថូស ១៥:៥៥-៥៧។ តើមានអ្វីកើតឡើងចំពោះ អំណាចនៃសេចក្ដីស្លាប់ ដោយសារអង្គព្រះយេស៊ូវ?

១០. តាមគំនិតរបស់លោកអ្នក តើព្រះយេស៊ូវត្រូវតែសុគតឬ? តើការសុគតរបស់ព្រះយេស៊ូវគ្រីស្ទមានភាពយុត្តិធម៌ដែរឬទេ? តើចម្លើយរបស់លោកអ្នក មានឥទ្ធិពលទៅលើរបៀបដែលលោកអ្នកមានទំនាក់ទំនងជាមួយនឹង ព្រះជាម្ចាស់យ៉ាងដូចម្ដេច?

## ការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ



១១. បន្ទាប់ពីព្រះយេស៊ូវបានសុគត ហើយ គេបញ្ចុះទ្រង់នៅក្នុងផ្នូររួចហើយ តើគេ បានធ្វើអ្វី ដើម្បីការពារផ្នូររបស់ទ្រង់? (ម៉ាថាយ ២៧:៦២-៦៦)

១២. សូមអានកណ្ឌគម្ពីរ ម៉ាថាយ ២៨:១-៧។ តើនៅថ្ងៃដំបូងនៃសប្តាហ៍នោះ គេបានឃើញអ្វីនៅឯផ្នូរ? តើពួកទេវតាបាននិយាយអ្វីខ្លះអំពីព្រះយេស៊ូវ?

១៣. តើគេបានសូកពួកទាហានឲ្យនិយាយបែបណា? (ម៉ាថាយ ២៨:១១-១៥)

> *ក្នុងនាមខ្ញុំជាមេធាវីម្នាក់ ខ្ញុំបានសិក្សាយ៉ាងស៊ីជម្រៅទៅលើភស្តុតាងនៃការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ។ ចំពោះខ្ញុំ ភស្តុតាងទាំងនោះពិតជាបញ្ជាក់យ៉ាងច្បាស់ថា ព្រះគ្រីស្ទបានរស់ឡើងវិញមែន។ ជារឿយៗ ខ្ញុំបានឈ្នះក្តីនៅឯតុលាការដោយសម្អាងលើភស្តុតាងបន្តិចបន្តួច ហើយមិនសូវច្បាស់ បើប្រៀបធៀបទៅនឹងភស្តុតាងនៃការសុគតរបស់ព្រះយេស៊ូវគ្រីស្ទ។ ខ្ញុំទទួលស្គាល់ភស្តុតាងដែលមានក្នុងកណ្ឌគម្ពីរ ដំណឹងល្អចំពោះការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទយ៉ាងអស់ពីចិត្តថាជាទីបន្ទាល់ពីមនុស្សដ៏ស្មោះត្រង់ ដែលបានសរសេរបញ្ជាក់អះអាងពីសេចក្តីពិត។*
>
> លោក អិដវើដ ខ្លាក (Edward Clarke)
> ដកស្រង់ចេញពីសៀវភៅ *Basic Christianity*

១៤. បន្ទាប់ពីព្រះគ្រីស្ទមានព្រះជន្មរស់ឡើងវិញហើយ ទ្រង់បានបង្ហាញព្រះអង្គទ្រង់មកឯពួកសិស្សរបស់ទ្រង់។

ក) តើពួកគេមានអារម្មណ៍ដូចម្ដេចពេលឃើញទ្រង់ដំបូង? (លូកា ២៤:៣៦-៣៧)

ខ) តើទ្រង់បានធ្វើអ្វីខ្លះ ដើម្បីបង្ហាញពួកគេថា ទ្រង់មានរូបកាយ? (លូកា ២៤:៣៩-៤៣)

១៥. ជាច្រើនសតវត្សមកហើយ មានមនុស្សជាច្រើនបានព្យាយាមបដិសេធ និងព្យាយាមបង្ហាញថា ទ្រង់មិនបានរស់ឡើងវិញនោះទេ ប៉ុន្តែគ្រីស្ទបរិស័ទជឿថា ការរស់ឡើងវិញរបស់ព្រះគ្រីស្ទគឺជាការដែលសំខាន់ជាងគេបំផុតចំពោះជំនឿរបស់ពួកគេ។

ក) សូមអានកណ្ឌគម្ពីរ ១កូរិនថូស ១៥:១៤-១៩។ ប្រសិនបើព្រះគ្រីស្ទមិនបានរស់ពីសុគតឡើងវិញទេ តើនឹងមានរឿងអ្វីកើតឡើង? ហើយតើមានការជាប់ទាក់ទងអ្វីខ្លះចំពោះអ្នកជឿ?

២) ឥឡូវសូមអានកណ្ឌគម្ពីរ ១កូរិនថូស ១៥:២០-២៦។ ប្រសិនបើព្រះគ្រីស្ទពិតជាបានរស់ពីសុគតវិញមែន តើនឹងមានអ្វីកើតឡើង? ហើយតើមានការជាប់ទាក់ទងអ្វីខ្លះចំពោះអ្នកជឿ?

> “*ព្រះជាម្ចាស់បានបំផ្លាញច្បាប់នៃបាប និងច្បាប់នៃការដាក់ទោស ដែលពីមុនជាច្បាប់ដែលមិនអាចលើកលែងបាន។ ទ្រង់បំផ្លាញច្បាប់នេះដោយការរុករានផែនដី ដោយការទទួលយកសេចក្តីអាក្រក់យ៉ាងសម្បើមពីមនុស្សតាមរយៈការសុគតលើឈើឆ្កាង ហើយបានរៀបចំសេចក្តីសង្គ្រោះសម្រាប់មនុស្សចេញពីការអាក្រក់នោះមក។ ភ្នំកាល់វ៉ារីជាកន្លែងដែលបានបញ្ឈប់សង្គ្រាមរវាងយុត្តិធម៌ និងការអត់ទោស។ ព្រះយេស៊ូវគ្រីស្ទដ៏បរិសុទ្ធបានបំផ្លាញភាពគ្មានព្រះគុណ ដោយទទួលយកនូវសេចក្តីក្រោធដែលទាមទារឲ្យមានយុត្តិធម៌។*
>
> លោក ភីលីព យេនស៊ី (Philip Yancey)
> ដកស្រង់ចេញពីសៀវភៅ *What's So Amazing About Grace?*

១៦. សូមអានកណ្ឌគម្ពីរ ហេព្រើរ ១២:១-៣។ តើលោកអ្នកគិតថា មានអ្វីដែលជំរុញព្រះហឫទ័យព្រះយេស៊ូវឲ្យទ្រាំទ្រនឹងការឈឺចាប់ដ៏ខ្លាំងបំផុតពីការក្បត់សេចក្តីអាម៉ាស់ និងការសុគតដូច្នេះ? តើការនេះមានន័យដូចម្តេចចំពោះលោកអ្នក?

១៧. ដោយសារលោកអ្នកដឹងថា ព្រះយេស៊ូវមានព្រះជន្មរស់ពីសុគត ហើយមានព្រះជន្មគង់នៅសព្វថ្ងៃនេះ តើការនេះមានន័យដូចម្តេចចំពោះលោកអ្នក?



១៨. សូមពន្យល់ពីសារៈសំខាន់នៃដំណឹងល្អ និងសេចក្តីសង្ឃឹមដែលលោកអ្នកបានទទួលតាមរយៈដំណឹងល្អនោះ។ (១កូរិនថូស ១៥:១-៥)

# សៀវភៅកំណត់ហេតុរបស់ខ្ញុំ

អស់រយៈពេលមួយសប្តាហ៍កន្លងមកហើយ តើសេចក្តីពិតដែលបញ្ជាក់ពីព្រះយេស៊ូវជាព្រះដ៏ពិតមានឥទ្ធិពលយ៉ាងដូចម្តេចចំពោះជីវិតរបស់លោកអ្នក? សូមពន្យល់៖

# ចំណុចគួរចងចាំ

- ព្រះយេស៊ូវបានប្រសូតនៅភូមិបេថ្លេហិម បានធំពេញវ័យនៅឯកាលីឡេ ហើយបានក្លាយជាជាងឈើម្នាក់។ ទ្រង់បានចំណាយពេល៣ឆ្នាំក្នុងការបម្រើមនុស្សរាប់ពាន់នាក់ និងបង្ហាញថា ទ្រង់គឺជាព្រះគ្រីស្ទ។
- បន្ទាប់មកគេបានកាត់ទោសទ្រង់ដល់ជីវិតដោយសុគតនៅលើឈើឆ្កាង ដើម្បីទទួលទោសជំនួសបាបរបស់យើង។
- បីថ្ងៃក្រោយមក ព្រះយេស៊ូវមានព្រះជន្មរស់ពីសុគតឡើងវិញ។ ការរស់ឡើងវិញរបស់ទ្រង់គឺជារឿងពិតមួយនៅក្នុងប្រវត្តិសាស្ត្រ។

# ការចូលឲ្យបានស៊ីជម្រៅ

ព្រះគម្ពីររៀបរាប់ពីការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវ គឺជារឿងប្រវត្តិសាស្ត្រដ៏ពិតប្រាកដ ដែលបានកើតឡើងក្នុងពេលវេលាដ៏ជាក់លាក់។ សូមកត់ចំណាំពីអ្នកដែលបានឃើញព្រះយេស៊ូវបន្ទាប់ពីព្រះជាម្ចាស់បានលើកទ្រង់ឡើងពីសុគតវិញតាមខគម្ពីរក្នុងតារាងខាងក្រោមនេះ៖

### សាក្សីពីការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវ

| ខយោង | ទីតាំង | សាក្សីដែលបានឃើញព្រះយេស៊ូវក្រោយពីការសុគត |
|---|---|---|
| យ៉ូហាន ២០:១៤-១៧ | ផ្នូរ | ម៉ារាជាអ្នកស្រុកម៉ាក់ដាឡា |
| ម៉ាថាយ ២៨:៨-៩ | ដើរចេញពីផ្នូរ | ស្រីៗ |
| លូកា ២៤:៣៦-៤៣ | ក្រុងយេរូសាឡិម | ពួកសាវ័ក១១នាក់ |
| យ៉ូហាន ២០:២៤-៣១ | នៅផ្ទះមួយ | សាវ័ក ថូម៉ាស |
| ម៉ាថាយ ២៨:១៦-១៧ | កាលីឡេ (ភ្នំ) | សាវ័កទាំង១១នាក់ |

| | | |
|---|---|---|
| លូកា ២៤:១៣-៣៥ | ផ្លូវទៅកាន់ភូមិ<br>អេម៉ោស | ក្លេវប៉ាស និង មិត្រ |
| យ៉ូហាន ២១:១-១៤ | សមុទ្រទីបេរាស | ពួកសិស្ស |
| ១កូរិនថូស ១៥:៥ | (ម្តុំក្រុងយេរូសាឡិម?) | សាវ័ក ពេត្រុស (កេផាស) |
| ១កូរិនថូស ១៥:៦ | (ម្តុំក្រុងយេរូសាឡិម?) | ប្រុសៗ៥០០នាក់ |
| ១កូរិនថូស ១៥:៧ | (ម្តុំក្រុងយេរូសាឡិម?) | សាវ័ក យ៉ាកុប |
| ១កូរិនថូស ១៥:៨ | តាមផ្លូវទៅកាន់<br>ក្រុងដាម៉ាស | លោក សូល<br>(ប្តូរឈ្មោះថាសាវ័ក ប៉ុល) |

តើសេចក្តីខាងលើនេះជួយលោកអ្នកឲ្យកាន់តែជឿជាក់លើព្រះគ្រីស្ទដ៏មានព្រះជន្មរស់យ៉ាងដូចម្តេចខ្លះ?

**ជំពូកទី**

# ៤

# ព្រះវិញ្ញាណដែលគង់នៅក្នុងលោកអ្នក

ព្រះយេស៊ូវបានរស់ពីសុគត ហើយមានព្រះជន្មរស់នៅរហូតដល់សព្វថ្ងៃនេះ! នៅពេលដែលព្រះយេស៊ូវបានយាងត្រឡប់ទៅឯស្ថានសួគ៌វិញ ពេលនោះពួកទេវតាបានទាយពីទំនាយដែលទ្រង់នឹងយាងត្រឡប់មកវិញនៅថ្ងៃណាមួយជាមិនខាន (កិច្ចការ ១:៩-១១)។ តែទ្រង់មិនបានទុកឲ្យអ្នកដែលដើរតាមទ្រង់នៅឯកោនោះឡើយ។ ទ្រង់បានបញ្ជូនព្រះវិញ្ញាណបរិសុទ្ធដែលជាបុគ្គលមួយអង្គទៀតនៃព្រះត្រៃឯក* ដល់ពួកគេ ដូច្នេះអ្នកដើរតាមព្រះគ្រីស្ទទាំងអស់នឹងមានអំណរពីព្រះវត្តមានរបស់ទ្រង់គ្រប់វិនាទី ហើយរស់នៅក្រោមឥទ្ធិពលនៃការបំផ្លាស់បំប្រែ និងការគ្រប់គ្រងរបស់ទ្រង់។

---

*ពាក្យ **ព្រះត្រៃឯក** គ្មាននៅក្នុងព្រះគម្ពីរទេ ប៉ុន្តែពួកអ្នកទេវវិទ្យាបង្កើតពាក្យនេះមក ដើម្បីបញ្ជាក់ពីការបង្រៀនក្នុងព្រះគម្ពីរទាំងមូលថា មានព្រះពិតតែមួយគត់ ហើយព្រះដ៏ពិតនោះ មានបុគ្គលបីអង្គ គឺព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ។

# ការយាងមករបស់ព្រះវិញ្ញាណបរិសុទ្ធ



១. នៅពេលដែលព្រះយេស៊ូវបានខិតខំរៀបចំសិស្ស ដើម្បីប្រឈមមុខនឹងការសុគតរបស់ទ្រង់ តើពួកគេមានអារម្មណ៍បែបណាពីអនាគតរបស់ខ្លួន? (យ៉ូហាន ១៤:១, ១៨)

២. តើព្រះយេស៊ូវបានទូលសូមព្រះវរបិតារបស់ទ្រង់ឲ្យធ្វើអ្វី ដើម្បីកំសាន្តចិត្តដល់ពួកសិស្ស? (យ៉ូហាន ១៤:១៦, ២៦)

៣. ព័ន្ធកិច្ច និងឥទ្ធិពលរបស់ព្រះយេស៊ូវនៅលើផែនដីនេះមិនមែនបញ្ចប់នៅត្រង់ការសុគត និងការយាងឡើងស្ថានសួគ៌វិញរបស់ទ្រង់នោះទេ តែពេលវេលានោះគឺជាពេលដែលព័ន្ធកិច្ច និងឥទ្ធិពលរបស់ទ្រង់ទើបនឹងចាប់ផ្តើមតែប៉ុណ្ណោះ!

តើព្រះយេស៊ូវបានសន្យាថានឹងនៅតែបន្តធ្វើកិច្ចការអ្វីខ្លះ ចំពោះអ្នកដើរតាមទ្រង់ បន្ទាប់ពីទ្រង់យាងឡើងស្ថានសួគ៌វិញ?

យ៉ូហាន ១៤:១-២

យ៉ូហាន ១៤:៣-៤

យ៉ូហាន ១៤:១៣-១៤

យ៉ូហាន ១៤:១៩

យ៉ូហាន ១៤:២៣

យ៉ូហាន ១៤:២៧

យ៉ូហាន ១៤:២៩

ហេតុអ្វីបានជាព្រះយេស៊ូវសន្យាពីការទាំងនេះចំពោះពួកគេ?

## ព័ន្ធកិច្ចរបស់ព្រះយេស៊ូវសព្វថ្ងៃ



៤. សូមអានកណ្ឌគម្ពីរ អេភេសូរ ១:២០-២៣។
តើសព្វថ្ងៃនេះព្រះយេស៊ូវគង់នៅឯណា ហើយទ្រង់កំពុងតែធ្វើអ្វី?

តើការនេះមានអត្ថន័យដូចម្ដេចចំពោះលោកអ្នកផ្ទាល់?

៥. តើមានអ្វីផ្សេងទៀតដែលព្រះគ្រីស្ទកំពុងតែធ្វើសម្រាប់យើងសព្វថ្ងៃនេះ? (រ៉ូម ៨:៣៤)

៦. ក្នុងសេចក្ដីអធិស្ឋានដ៏អស្ចារ្យរបស់ព្រះយេស៊ូវដែលបានកត់ទុកនៅក្នុងកណ្ឌគម្ពីរ យ៉ូហាន ១៧ តើទ្រង់បានទូលសូមអ្វីខ្លះពីព្រះវរបិតាសម្រាប់អស់អ្នកដែលដើរតាមទ្រង់?

ខ១៣

ខ១៥

ខ១៧

ខ២១

ខ២៤

៧. តើលោកអ្នកគិតថាសព្វថ្ងៃនេះព្រះយេស៊ូវកំពុងតែអធិស្ឋានសម្រាប់លោកអ្នកដូចកាលពីមុនដែរឬទេ?
សូមអានកណ្ឌគម្ពីរ ហេព្រើរ ៧:២៤-២៥ បន្ទាប់មកសូមពន្យល់៖

*ព្រះយេស៊ូវមានព្រះជន្មរស់សព្វថ្ងៃនេះ! ទ្រង់សោយរាជ្យនៅឯស្ថានសួគ៌។ ទ្រង់កំពុងតែធ្វើការ។ ទ្រង់កំពុងតែអធិស្ឋានសម្រាប់យើងរាល់គ្នា ហើយនិងតម្រង់ជំនឿរបស់យើងឲ្យល្អបំផុត។ ព្រះយេស៊ូវមិនមែនជា "ខ្មោចឆៅ" ទេ។*

លោក ដែននីស ស្តូខស៍ (Dennis Stokes)

៨. តើមានការអ្វីផ្សេងទៀតដែលព្រះយេស៊ូវកំពុងធ្វើសព្វថ្ងៃនេះ? សូមអានកណ្ឌគម្ពីរ អេភេសូរ ៥:២៥-២៧។ តើលោកអ្នកបានទទួលបទពិសោធន៍យ៉ាងដូចម្តេច ពីការដែលព្រះយេស៊ូវធ្វើឲ្យលោកអ្នកបានបរិសុទ្ធ ហើយឥតកន្លែងបន្ទោសបាននោះ?

*បុគ្គលនីមួយៗនៃព្រះត្រៃឯកតែងតែធ្វើការជាមួយគ្នា។ គ្រប់ទាំងសកម្មភាពរបស់ព្រះជាម្ចាស់គឺសម្រេចបានដោយបុគ្គលទាំងបីអង្គ។*

លោក អេ. ដាប់បិលយូ. ថូហ្ស៊័រ (A. W. Tozer)

# ការសណ្ឋិតរបស់ព្រះវិញ្ញាណបរិសុទ្ធ



៩. តើអ្នកជឿគ្រប់គ្នាមានចំណុចដូចគ្នាអ្វីខ្លះ?

រ៉ូម ៨:៩

១កូរិនថូស ២:១២

១កូរិនថូស ៣:១៦

ទីតុស ៣:៥-៦

តើលោកអ្នកឆ្លើយតបចេញពីចិត្តរបស់លោកអ្នកចំពោះការនេះយ៉ាងដូចម្ដេច?

១០. ហេតុអ្វីបានជាទ្រង់ចាត់ព្រះវិញ្ញាណទ្រង់មកសណ្ឋិតក្នុងអ្នកជឿ? សូមគូសរង្វង់ទៅលើអក្សរដែលជាចម្លើយត្រឹមត្រូវ។ (កាឡាទី ៤:៦)

ក) ពីព្រោះអ្នកជឿបានធ្វើបុណ្យជ្រមុជទឹក។

ខ) ពីព្រោះអ្នកជឿគឺជាកូនរបស់ទ្រង់។

គ) ពីព្រោះអ្នកជឿបានលះបង់ជីវិតរបស់គេថ្វាយទ្រង់។

ឃ) ពីព្រោះអ្នកជឿមានបទពិសោធន៍យ៉ាងពិសេសមួយ។

១១. តើមានលទ្ធផលអ្វីខ្លះចំពោះអស់អ្នកណាដែលមានព្រះវិញ្ញាណបរិសុទ្ធ
គង់នៅជាមួយ? (២ធីម៉ូថេ ១:៧)

## ការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធ

១២. កណ្ឌគម្ពីរ កាឡាទី ៥:១៦-១៧ បកស្រាយពីទំនាស់នៅក្នុងជីវិតរបស់
យើងរវាង ______________________________ និង _______
____________________________________។

តើនរណាគួរតែជាអ្នកគ្រប់គ្រងលើជីវិតរបស់លោកអ្នក?

ការធ្វើពិសោធន៍ខាងក្រោមនេះគឺជាការបង្ហាញនៃអំណាចដែលជាលទ្ធផលពីការភ្ជាប់គ្នា រវាងព្រះវិញ្ញាណបរិសុទ្ធ និងអ្នកជឿ៖

> *ខ្ញុំមានសំណមួយដុំក្នុងដៃ។ ខ្ញុំកាន់វានៅលើអាងទឹក ហើយខ្ញុំលាដៃ។ សំណនោះច្បាស់ជាធ្លាក់ចូលទៅក្នុងទឹក ហើយលិចចូលទៅដល់បាតអាង។ ច្បាប់នៃទំនាញផែនដីបានគ្រប់គ្រងលើវា។ ខ្ញុំយកសំណដដែលនេះមកភ្ជាប់ជាមួយនឹងដុំឈើមួយដុំ ហើយទម្លាក់វាទៅក្នុងអាងទឹកម្តងទៀត។ វាក៏អណ្តែត។ មិនមានអ្វីផ្លាស់ប្តូរទៅលើលក្ខណៈធម្មជាតិរបស់ដុំសំណនោះទេ ហើយក៏មិនមានការផ្លាស់ប្តូរលើច្បាប់នៃទំនាញផែនដីនោះដែរ ប៉ុន្តែតាមរយៈការចងផ្គោបជាមួយនឹងដុំឈើច្បាប់មួយទៀតដែលខ្លាំងជាងច្បាប់នៃទំនាញផែនដីបានគ្រប់គ្រងលើដុំសំណនោះ គឺច្បាប់នៃការអណ្តែតដែលបណ្តាលឲ្យសំណនោះឃ្លាតចេញពីការគ្រប់គ្រងនៃច្បាប់ទំនាញផែនដី។*
>
> លោក ជេ. អស្វលដ៍ សេនឌ័រស៍ (J. Oswald Sanders)*

១៣. តើលោកអ្នកកត់សម្គាល់ឃើញអ្វីខ្លះ អំពីព្រះវិញ្ញាណបរិសុទ្ធដែលកំពុងដឹកនាំយើងនៅក្នុងខគម្ពីរខាងក្រោមនេះ?

យ៉ូហាន ១៤:២៥-២៧

* មកពី J. Oswald Sanders, *The Holy Spirit and His Gifts* (Grand Rapids, MI: Zondervan, ឆ្នាំ១៩៤០), ទំព័រ៥៧។

យ៉ូហាន ១៦:៧-៨

យ៉ូហាន ១៦:១២-១៥

១៤. តើព្រះវិញ្ញាណបរិសុទ្ធប្រើអ្វី ដើម្បីឲ្យយើងស្គាល់សេចក្តីពិត? (អេភេសូរ ៦:១៧)

១៥. សូមអានកណ្ឌគម្ពីរ ហេព្រើរ ៤:១២-១៣។ តើលោកអ្នកមានអារម្មណ៍បែបណាពីការដែលព្រះជាម្ចាស់មើលឃើញអ្វីៗទាំងអស់? តើព្រះវិញ្ញាណបរិសុទ្ធអាចប្រើសេចក្តីនេះនៅក្នុងជីវិតរបស់លោកអ្នកយ៉ាងដូចម្តេច?

១៦. តើព្រះវិញ្ញាណបរិសុទ្ធជួយយើងតាមរយៈ
ការអ្វីទៀត? (រ៉ូម ៨:២៦)



១៧. ក្នុងកណ្ឌគម្ពីរ កិច្ចការ ១:៨ ព្រះយេស៊ូវបានប្រើឃ្លាថា «អ្នករាល់គ្នានឹង» ពីរដង។ ទ្រង់បានមានបន្ទូលពីហេតុការណ៍ដែលនឹងកើតមានឡើង នៅពេលដែលព្រះវិញ្ញាណបរិសុទ្ធយាងមកសណ្ឋិតលើពួកសិស្ស។

ក) តើព្រះយេស៊ូវមានបន្ទូលទៅកាន់ពួកសិស្សរបស់ទ្រង់ថា ពួកគេនឹងមានអ្វី ហើយនិងធ្វើជាអ្វី?

ខ) តើលោកអ្នកបានទទួលបទពិសោធន៍ពីការដែលព្រះវិញ្ញាណបរិសុទ្ធប្រទានព្រះចេស្តា ឬក៏ប្រទានកម្លាំងដល់លោកអ្នកយ៉ាងដូចម្តេច?

គ) តើព្រះវិញ្ញាណបរិសុទ្ធជួយលោកអ្នកក្នុងការប្រកាសដំណឹងល្អពីព្រះយេស៊ូវ ហើយនិងការនិយាយជាមួយអ្នកដទៃពីជំនឿរបស់លោកអ្នកដោយរបៀបណា?

១៨. សូមរំឮកសំណួរទី ៩-១៧ ឡើងវិញ។ តើមានអ្វីធានាចំពោះលោកអ្នកថាព្រះវិញ្ញាណបរិសុទ្ធគង់នៅក្នុងជីវិតលោកអ្នក? តើព្រះវិញ្ញាណបរិសុទ្ធមានឥទ្ធិពលចំពោះជីវិតរស់នៅរបស់លោកអ្នកនៅក្នុងសប្តាហ៍កន្លងទៅនេះយ៉ាងដូចម្តេច?

# ការពេញដោយ
# ព្រះវិញ្ញាណបរិសុទ្ធ



១៩. តើលោកអ្នកអាចកត់សម្គាល់អ្វីបានខ្លះ អំពីការពេញដោយ ព្រះវិញ្ញាណបរិសុទ្ធ? (កិច្ចការ ១៣:៥២ និង អេភេសូរ ៥:១៨)

ជីវិតដែលបានបំពេញដោយព្រះវិញ្ញាណគឺ៖

- ជីវិតមួយនៃការស្តាប់បង្គាប់ចំពោះព្រះវិញ្ញាណបរិសុទ្ធ (សំណួរទី ១១, ១២)
- ជីវិតមួយដែលយកព្រះគ្រីស្ទធ្វើជាគោល (សំណួរទី ៤, ៨)
- ជីវិតមួយដែលពឹងលើព្រះបន្ទូលដ៏រស់របស់ព្រះជាម្ចាស់ (សំណួរទី ១៤, ១៥)
- ជីវិតមួយដែលពេញដោយការអធិស្ឋាន (សំណួរទី ៦, ១៦)
- ជីវិតមួយដែលពេញដោយការប្រកបគ្នា (សំណួរទី ២០)
- ជីវិតមួយដែលធ្វើតាមគំរូរបស់ព្រះយេស៊ូវ និងចែកចាយពីទ្រង់ (សំណួរទី ១៧, ២០)




រូបកង់រទេះដែលបានបង្ហាញខាងលើនេះ គឺជាវិធីមួយដែលជួយឲ្យលោកអ្នកចងចាំនូវសេចក្តីពិតជាមូលដ្ឋាននៃជីវិតដែលពេញដោយព្រះវិញ្ញាណ។ ជីវិតដែលពេញដោយ **ការស្តាប់បង្គាប់** ជាជីវិតដែលព្រះវិញ្ញាណបរិសុទ្ធបណ្តាលឲ្យយើងយក **ព្រះគ្រីស្ទ**ធ្វើជាចំណុចកណ្តាលនៃជីវិត ប្រៀបបានជាដុំកណ្តាលនៃកង់រទេះដែលមានដូចរូបខាងលើ។ **ព្រះបន្ទូល**របស់ព្រះជាម្ចាស់ និង **ការអធិស្ឋាន** នឹងជួយសង់ទំនាក់ទំនងរបស់លោកអ្នកជាមួយព្រះគ្រីស្ទ ដូច្នេះទ្រង់អាចគង់នៅជាមួយលោកអ្នក ហើយឈោងចាប់អ្នកដទៃទៀតតាមរយៈ**ការប្រកប** និង **ការធ្វើបន្ទាល់**របស់លោកអ្នក។

ឯព្រះបន្ទូល ការអធិស្ឋាន ការប្រកប និងការធ្វើបន្ទាល់ប្រៀបបានទៅនឹងកាំរទេះដែលបញ្ជាក់ថា អ្នកដែលដើរតាមព្រះគ្រីស្ទត្រូវតែមានចំណុចទាំងបួនដែលភ្ជាប់ទៅនឹងព្រះគ្រីស្ទ ដើម្បីឲ្យជីវិតមានដំណើរការល្អជាមួយព្រះជាម្ចាស់។ ព្រះវិញ្ញាណបរិសុទ្ធប្រើចំណុចទាំងបួន ដើម្បីសម្រេចបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងដើម្បីជួយយើងឲ្យមានការលូតលាស់ខាងវិញ្ញាណ។

២០. សូមអានកណ្ឌគម្ពីរ កិច្ចការ ៤:៣១-៣៥ ហើយសរសេរចុះនូវគំរូពីរបៀបរស់នៅរបស់សិស្សព្រះយេស៊ូវដែលបានបង្ហាញពីគោលការណ៍នៃរង្វង់កង់រទេះខាងលើនេះ។

# សៀវភៅកំណត់ហេតុរបស់ខ្ញុំ

នៅពេលដែលលោកអ្នកសញ្ជឹងគិតទៅលើព័ន្ធកិច្ច និងការសណ្ឋិតនៅរបស់ព្រះវិញ្ញាណបរិសុទ្ធលើលោកអ្នក តើលោកអ្នកមានអារម្មណ៍ថា លោកអ្នកស័ក្តិសមនឹងទទួលព្រះគុណរបស់ព្រះជាម្ចាស់ដែរឬទេ? តើការទទួលយកព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះជាម្ចាស់ដែលសណ្ឋិតក្នុងលោកអ្នក មើលទៅគួរឲ្យខ្លាច ឬក៏ជាការដែលធ្វើឲ្យលោកអ្នកមានភាពកក់ក្តៅ? សូមបង្ហាញពីរបៀបដែលការនេះអាចនឹងមានឥទ្ធិពលលើទំនាក់ទំនងរបស់លោកអ្នកជាមួយព្រះជាម្ចាស់។

## ចំណុចគួរចងចាំ

- ព្រះយេស៊ូវគ្រីស្ទបានសន្យាថា បន្ទាប់ពីទ្រង់យាងទៅ ទ្រង់នឹងរៀបចំកន្លែងមួយសម្រាប់អ្នកជឿគ្រប់ៗរូប ហើយនិងបញ្ជូនព្រះវិញ្ញាណបរិសុទ្ធមក ដើម្បីទុកជាអ្នកជំនួយដល់យើង។

- ព្រះគ្រីស្ទគង់នៅខាងស្តាំព្រះវរបិតា ហើយសោយរាជ្យលើគ្រប់ទាំងរបស់ដែលទ្រង់បានបង្កើតមក និងក្រុមជំនុំរបស់ទ្រង់។

- ព្រះយេស៊ូវកំពុងតែអធិស្ឋានជាបន្តបន្ទាប់សម្រាប់អស់អ្នកដែលដើរតាមទ្រង់ ហើយទ្រង់ក៏កំពុងបង្កើនជំនឿរបស់ពួកគេឡើងថែមទៀតផងដែរ។

- សព្វថ្ងៃនេះព្រះវិញ្ញាណយាងមកគង់នៅជាមួយ ដឹកនាំ និងបំពេញគ្រប់ទាំងអ្នកជឿម្នាក់ៗ។

- ព្រះវិញ្ញាណបរិសុទ្ធប្រទានអំណាចដល់យើង ដើម្បីឲ្យយើងរស់នៅក្នុងជីវិតដែលចេះស្តាប់បង្គាប់ ពោលគឺជាជីវិតមួយដែលមានព្រះគ្រីស្ទជាគោល។

# ការចូលឲ្យបានស៊ីជម្រៅ

ព្រះវិញ្ញាណបរិសុទ្ធគឺជាបុគ្គលនៃព្រះត្រៃឯកមួយអង្គដែលមានបុគ្គលិកលក្ខណៈដោយអង្គទ្រង់ផ្ទាល់។ ខគម្ពីរខាងក្រោមនេះអាចជួយលោកអ្នកឲ្យស្គាល់ព្រះវិញ្ញាណបរិសុទ្ធកាន់តែច្បាស់។ សូមជ្រើសរើសខគម្ពីរមួយចំនួនដែលលោកអ្នកចាប់អារម្មណ៍។ សូមពិចារណាទៅលើខគម្ពីរខាងក្រោម បន្ទាប់មកសូមសរសេរចុះពីការឆ្លើយតបរបស់លោកអ្នកទៅលើខនីមួយៗ។

| ព្រះវិញ្ញាណបរិសុទ្ធ | ខយោង | តើខនេះមានអត្ថន័យដូចម្តេចចំពោះលោកអ្នក? |
|---|---|---|
| ជួយអង្វរជំនួស | រ៉ូម ៨:២៦ | |
| មានព្រះបន្ទូល | កិច្ចការ ១៣:២ | |
| បង្រៀន | យ៉ូហាន ១៤:២៦ | |
| ស្រឡាញ់ | រ៉ូម ១៥:៣០ | |
| គិត | ១កូរិនថូស ២:១០-១១,<br>រ៉ូម ៨:២៧ | |

| | | |
|---|---|---|
| សព្វព្រះហឫទ័យ | ១កូរិនថូស ១២:១១ | |
| ព្រះទ្រង់ដឹកនាំ | រ៉ូម ៨:១៤ | |
| គេអាចទាស់ទទឹង<br>នឹងទ្រង់បាន | កិច្ចការ ៧:៥១ | |
| គេអាចល្បួង ឬក៏<br>បង្កហេតុនឹងទ្រង់បាន | កិច្ចការ ៥:៩ | |
| គេអាចត្មះតិះដៀល<br>ទ្រង់បាន | ហេព្រើរ ១០:២៩ | |
| គេអាចប្រមាថ<br>ទ្រង់បាន | ម៉ាថាយ ១២:៣១-៣២ | |
| គេអាចធ្វើឲ្យទ្រង់ព្រួយ<br>ព្រះហឫទ័យបាន | អេភេសូរ ៤:៣០ | |
| គេអាចពន្លត់ទ្រង់បាន | ១ថែស្សាឡូនីច ៥:១៩ | |

## សៀវភៅសិក្សាព្រះគម្ពីរដ៏មានសារៈសំខាន់សម្រាប់អ្នកដើរតាមព្រះគ្រីស្ទនៅក្នុងសតវត្សទី២១



គបស២

**អ្នកដើរតាមព្រះយេស៊ូវដែលពេញដោយព្រះវិញ្ញាណ** 978-0-9890481-1-8

លោកអ្នកនឹងរៀនចេះពីអត្ថន័យនៃការពេញដោយព្រះវិញ្ញាណបរិសុទ្ធ ដើម្បីឲ្យការស្តាប់បង្គាប់ ការសិក្សាព្រះគម្ពីរ ការអធិស្ឋាន ការប្រកបគ្នា និងការធ្វើបន្ទាល់ ក្លាយទៅជាទម្លាប់ និងមានន័យពេញលេញនៅក្នុងជីវិតរស់នៅរបស់លោកអ្នក។



គបស៣

**ការដើរជាមួយព្រះគ្រីស្ទ** 978-0-9890481-2-5

លោកអ្នកនឹងរៀនចេះពីចំណុចសំខាន់ៗប្រាំយ៉ាងតាមរយៈសៀវភៅសិក្សាព្រះគម្ពីរដ៏ងាយស្រួលយល់នេះ ដើម្បីឲ្យបានក្លាយជាសិស្សរបស់ព្រះគ្រីស្ទដ៏រឹងមាំ និងកាន់តែពេញវ័យឡើង។



គបស៤

**អត្តចរិតរបស់អ្នកដើរតាមព្រះយេស៊ូវ** 978-0-9890481-3-2

សៀវភៅដ៏ងាយស្រួលយល់នេះនឹងជួយឲ្យលោកអ្នកយកទៅអនុវត្តលើគុណសម្បត្តិ និងគុណតម្លៃនៃភាពជាសិស្សរបស់ព្រះគ្រីស្ទក្នុងការរស់នៅ។



គបស៥

**មូលដ្ឋានគ្រឹះនៃជំនឿ** 978-0-9890481-4-9

សៀវភៅនៃការសិក្សាព្រះគម្ពីរនេះនឹងជួយលោកអ្នកឲ្យយល់ពីព្រះជាម្ចាស់ ព្រះបន្ទូលរបស់ទ្រង់ ព្រះវិញ្ញាណបរិសុទ្ធ និងការតយុទ្ធខាងព្រលឹងវិញ្ញាណ ព្រមទាំងការយាងមកវិញរបស់ព្រះគ្រីស្ទ។



គបស៦

**ការរីកចម្រើនក្នុងភាពជាសិស្សរបស់ព្រះយេស៊ូវ** 978-0-9890481-5-6

ការសិក្សាព្រះគម្ពីរពីសៀវភៅនេះនឹងផ្តល់នូវការយល់ដឹងដ៏ជ្រៅជ្រះ ព្រមទាំងការលើកទឹកចិត្ត ដើម្បីជួយឲ្យលោកអ្នកមានការលូតលាស់ក្នុងនាមជាសិស្សដ៏ពិតរបស់ព្រះគ្រីស្ទតាមរយៈការចែកចាយព្រះពរដល់អ្នកដទៃដែលព្រះជាម្ចាស់បានប្រទានមកលោកអ្នក។



គបស៧

**សេចក្តីសង្ឃឹមរបស់យើងនៅក្នុងព្រះគ្រីស្ទ** 978-0-9890481-6-3

សៀវភៅនៃការសិក្សាកណ្ឌគម្ពីរ ១ថែស្សាឡូនីចនេះ នឹងផ្តល់ជាគំរូដល់លោកអ្នកក្នុងការសិក្សាកណ្ឌគម្ពីរផ្សេងទៀតក្នុងព្រះគម្ពីរ ហើយលោកអ្នកនឹងទទួលបានគោលការណ៍នៃការសិក្សាព្រះគម្ពីរដ៏មានឥទ្ធិពលដែលលោកអ្នកអាចប្រើប្រាស់បានពេញមួយជីវិត។



គបស **សៀវភៅសម្រាប់គ្រូ** 978-0-9890481-7-0

សៀវភៅនេះនឹងផ្តល់នូវការយល់ដឹងដ៏ជ្រៅជ្រះដល់គ្រូបង្រៀន និងព័ត៌មានផ្សេងៗដែលគ្រូបង្រៀនត្រូវដឹង ដើម្បីបង្រៀនពីចំណុចសំខាន់នៃភាពជាសិស្សដ៏ពិតជាមួយអ្នកផ្សេងទៀត ទោះបីជាត្រូវបង្រៀនម្នាក់ទល់ម្នាក់ ឬក៏បង្រៀនជាក្រុម។

NAVPRESS
Discipleship Inside Out®

ប្រសិនបើលោកអ្នកចង់ជាវសៀវភៅនេះ សូមចូលទៅកាន់គេហទំព័រ
For purchase information please visit
www.cambodianchristianresources.com/dfd